ចេត្រ-ដែម

អធិការបឋមសិក្សាបារាំង - ខ្មែរ

# វិធីរៀនមើល-សរសេរ



## អក្សរសាស្ត្រខ្មែរ តាមរបៀបថ្មី សម្រាប់ថ្នាក់

# កុមារដ្ឋាន

DEUXIÈME EDITION

IMPRIMERIE HENRY

រក្សាសិទ្ធិ

CA1

# NOUVELLE MÉTHODE
# DE
# LECTURE & D'ÉCRITURE KHMÈRES
# POUR
# LES DÉBUTANTS

par

CHET - CHHEM
INSPECTEUR DE L'ENSEIGNEMENT PRIMAIRE
FRANCO - KHMER

TOUS DROITS RÉSERVÉS

ប្រកាសលេខ ៣.៦១៤ ចុះថ្ងៃទី ២២ ធ្នូ គ. ស. ១៩៥២ នៃរដ្ឋមន្ត្រីក្រសួងសិក្សាធិការ
បានបញ្ចូលសៀវភៅនេះ ទៅក្នុងពួកសៀវភៅសិក្សាទូទៅក្នុងសាលារៀន
ក្នុងសាធារណរដ្ឋខ្មែរ

# វិធីរៀនមើល-សរសេរ

## អក្សរសាស្ត្រខ្មែរ តាមរបៀបថ្មី សម្រាប់ថ្នាក់

# កុមារដ្ឋាន


អ្នកនិពន្ធ

**ចេត្រ-ឆែម**

អធិការបឋមសិក្សា បារាំង - ខ្មែរ



ការផ្សាយរបស់



រក្សាសិទ្ធិ



ព. ស. ២៤៩៦ — គ. ស. ១៩៥៣

## CONSEIL DES MINISTRES

### PRAKAS

N° 3614

.................. le Ministre
de l'Education Nationale, de la Jeunesse
et des Beaux Arts

Vu la Constitution ............

Vu le Traité Franco-Khmer du 8 Novembre 1949 et ses Accords d'application du 15 Juin 1950;

Vu le Kret N° 252–NS du 15 Juin 1952, modifié par ceux N° 254-NS et 354-NS des 17 Juin et 8 Août 1952, et le Kret N° 440-NS du 20 Septembre 1952, portant nomination du Cabinet ministériel;

Vu le Procès-Verbal en date du 9 Décembre 1952 de la Commission nommée par Prakas N° 2731 du 17 Décembre 1951;

Sur la proposition du Directeur de l'Instruction Publique.

**ARRETE :**

*ARTICLE PREMIER* — Le manuel ayant pour titre វិធីរៀនមើល-សរសេរអក្សរសាស្ត្រខ្មែរតាមរបៀបថ្មី សំរាប់ថ្នាក់កុមារដ្ឋាន (Nouvelle Méthode de Lecture et d'Ecriture Khmère pour les débutants) préparé par M. CHET-CHHEM, Inspecteur de l'Enseignement Primaire Franco-Khmer, est ajouté à la liste des manuels et publications scolaires dont l'usage est autorisé dans les écoles publiques ..............

*ARTICLE 2.*— Le Chef de Cabinet et le Directeur de l'Instruction Publique sont chargés, chacun en ce qui le concerne, de l'exécution du présent Prakas.

**Phnom-Penh, le 22 Décembre 1952**
*Signé :* ...............
PENG-PAS YUKANTHOR

**Pour copie conforme :**
*P. le Secrétaire Général*
*du Conseil des Ministres et p. o.*
*Le Secrétaire Général Adjoint,*
Signé : SAN-THIEU

**Pour Ampliation :**
*Le Chef de Cabinet,*
Signé : YEIM-YISINN

# អារម្ភកថា

ក្នុងសៀវភៅទំនើបនេះ យើងពុំបានយកតួព្យញ្ជនៈរៀងតាមវគ្គមកបំបែកជាមួយនឹងស្រៈទេ ។ យើងយកព្យញ្ជនៈជាអឃោសៈមកបំបែកមុន ទើបយកព្យញ្ជនៈជាឃោស មកបំបែកជាក្រោយ ។

ក្នុងពួកអឃោសៈក្តី ក្នុងពួកឃោសៈក្តី យើងយកតួព្យញ្ជនៈស្រដៀង ៗ គ្នា មកបញ្ចូលក្នុងមេរៀនតែមួយ ដើម្បីឲ្យសិស្សស្រួលចំណាំ ដូចជា (ក) នឹង (គ) ។

បើកាលណាគ្រូបានសរសេរតួព្យញ្ជនៈមួយយ៉ាងធំនៅលើក្តារខៀនបញ្ឈរ ដូចជា (ក) រួចសិស្សបានកសដែងទេ សរសេរលើក្តារធ្នំត្រឹមត្រូវហើយ គ្រូត្រូវយកព្យញ្ជនៈមួយតួទៀត ស្រដៀងគ្នានឹងព្យញ្ជនៈដើម មកសរសេរនៅខាងស្តាំ ដូចជា (គ) ។

គ្រូឲ្យសិស្សប្រៀបប្រដូចតួមុនទៅនឹងតួក្រោយ ឲ្យរកត្រង់ណាដែលដូចគ្នា គេថែមអ្វីទៅលើតួមុន ទើបកើតបានជាតួក្រោយ ។

ឧបមា : (ក) នឹង (គ) មានរាងតួដូចគ្នា តែ (គ) មានកូបរង់មូលនៅក្នុងពីខាងដើម ។

លុះសិស្សចំណាំព្យញ្ជនៈក្នុងមេរៀនទីមួយ ៗ បានហើយ ទើបចាប់បំបែកទៅតាមរបៀបប្រើស្រៈនឹងព្យញ្ជនៈ ។

ការរៀបរៀងសៀវភៅនេះ កើតឡើងបានជាបែបផែនដូច្នេះ ដោយសារអាស្រ័យនូវសេចក្ដីបំភ្លឺរបស់លោក ឈឹម-សុទ្ធ សាស្ត្រាចារ្យខាងវិជ្ជាបារាំងនៅសាលាបាលីជាន់ខ្ពស់ នៅភ្នំពេញ ដែលជាអ្នកធ្លាប់ប្រសប់ពិសោធឈ្លាសវៃក្នុងផ្លូវការសិក្សា ។

នៅទីបំផុតនេះ យើងសូមថ្លែងអំណរយ៉ាងឧត្ដមចំពោះ លោក ឈឹម-សុទ្ធ ។

# សេចក្ដីកត់ហេតុ (ស្រង់)

គណៈកម្មការបានពិនិត្យសៀវភៅនេះ គ្រប់សណ្ដានរៀនហូរហែទៅ ឃើញថា ក្នុងសៀវភៅនេះ មានរបៀបមួយយ៉ាងល្អដែរ ៖

១ ១– ញែកយក "ព្យញ្ជនៈ" សម្លេង "អឃោសៈ" រួចសម្លេង "ឃោសៈ" មកផ្សំនឹង "ស្រៈនិស្ស័យ" តាមដោយពួកនេះជាការងាយដល់កុមារនឹងស្វាធ្យាយ មួយយ៉ាង ។

១ ២– ជ្រើសយក "ព្យញ្ជនៈ" ណាដែលមានរូបភាពស្រដៀងគ្នាមកដាក់ផ្គូនឹងគ្នា នេះជាការអាចឲ្យកុមារងាយចំណាំ មួយយ៉ាងទៀតដែរ ។

រីឯបទទាំងឡាយក្នុងភាគទី ២ សមប្រកបនឹងថ្នាក់ "កុមារដ្ឋាន" ទាំងអស់ ។

សេចក្ដីកត់ហេតុនេះ ធ្វើនៅថ្ងៃទី ៩ ខែធ្នូ គ.ស. ១៩៥២

| សមាជិក | អនុប្រធានគណៈកម្មការ |
|---|---|
| ហត្ថលេខា ៖ អ៊ុំ-ឈុំ, ស្រី ស៊ុំ, មាស់-ឈឿន, ផេង-ជ្រីវ, មី-នាង, ព្រំ-មុត, ស្វាយ-អ៊ុន | ហត្ថលេខា ៖ ឈឹម-សុទ្ធ |

# សេចក្ដីណែនាំ

លោកជាគ្រូបង្រៀន ត្រូវរកក្រដាសក្រាស់ពណ៌ស កង ៤ ជ្រុងទ្រវែង បណ្ដោយ ១៤ ស.ម. ទទឹង ១០ ស.ម. ។

១)- យកក្រដាសនោះ មកចោះប្រហោង ៤ ជ្រុងទ្រវែង ទទឹង ៥ ស.ម. បណ្ដោយ ៦ ស.ម. ឲ្យចំកណ្ដាលក្រដាស ហើយសរសេរស្រៈនិស្ស័យលើផ្ទៃក្រដាសនោះពីខាងមុខ ឬពីខាងក្រោយ ពីខាងលើ ឬពីខាងក្រោមប្រហោងដែលចោះ តាមភាពស្រៈ ដូចបែបគំរូខាងក្រោមនេះ ។

នៅលើផ្ទៃម្ខាងទៀត សរសេរស្រៈមួយផ្សេងទៀត គឺជាការល្អដែរ ដើម្បីចំណេញក្រដាស ។



២)- យកក្រដាសមួយសន្ទឹកទៀត មកសរសេរព្យញ្ជនៈ ១ តួមាន ឲ្យចំកណ្ដាល ល្មមទឹងប្រហោងដែលបោះផ្ដើស្រៈនោះ ដូចមានគំនូរខាងក្រោមនេះ ។




## របៀបបង្រៀនសរសេរតួអក្សរ

ឧបមាដូចជាបង្រៀនអក្សរ «ត» លោកជាគ្រូត្រូវ

ក— សរសេរតួអក្សរយ៉ាងធំនៅលើក្ដារខៀនបង្ហាញសិស្ស ។

ខ— នាំសិស្សឲ្យវាសតួអក្សរនេះនឹងដៃទទេ ។

គ— ចាត់សិស្សម្នាក់ ឲ្យទៅសរសេរនៅលើក្ដារខៀន ដើម្បីឲ្យសិស្សឯទៀតកែ ឲ្យបានត្រឹមត្រូវឡើង ។

ឃ— ឲ្យសិស្សទាំងអស់គ្នាសរសេរលើក្ដារឆ្នួនលើកបង្ហាញគ្រូ ។
បើសិស្សណាសរសេរមិនត្រឹមត្រូវ លោកជាគ្រូត្រូវបង្គាប់ឲ្យសិស្សនោះកែឲ្យបានត្រឹមត្រូវឡើង ។

# របៀបប្រើព្យញ្ជនៈនឹងស្រៈដែលសរសេរលើក្រដាសក្រាស់

ឧបមាដូចជាបង្រៀនបំបែកអក្សរ "ត" លោកជាគ្រូត្រូវ ,

ក— លើកស្រៈ "េ ៀ" បង្ហាញសិស្សហើយសួរថា : នេះស្រៈអ្វី ?

១— យកក្រដាសដែលសរសេរតួអក្សរ "ត" មកដាក់ពីក្រោយក្រដាសដែលសរសេរស្រៈ "េ ៀ" ដូចបែបខាងក្រោមនេះ




គ— សួរសិស្សថា : នេះគេអានថាដូចម្ដេច ? ឆ្លើយថា : (តៀ) លោកគ្រូត្រូវសរសេរឲ្យច្បាស់ព្យាង្គនេះនៅលើក្ដារខៀនបញ្ឈរ ។

យូរ ៗ ម្ដង, គ្រូត្រូវប្រើរបៀបនេះ គឺឲ្យសិស្សរើសរកស្រៈមកផ្សំនឹងតួព្យញ្ជនៈ ដើម្បីឲ្យកើតជាព្យាង្គណាមួយ តាមចិត្តគ្រូរើស ។

# ភាគទី ១

មេរៀនទី - ១ អ អា

មេរៀនទី - ២ អិ អី

មេរៀនទី - ៣ អឹ អឺ

មេរៀនទី - ៤ អុ អូ អួ

មេរៀនទី - ៥ អើ អឿ អៀ អេ

មេរៀនទី - ៦ អែ អៃ អោ អៅ

មេរៀនទី - ៧ អុំ អំ អាំ អះ

មេរៀនទី - ៨ អុះ អេះ អោះ

## មេរៀនទី ៩ (សាឡើងវិញ)

អី អេះ អៅ អុំ

អែ អួ អៀ អើ ។

អាំ អាអាំ អេះ អុះ ។

អា អំ អេះ អី ។ អា អាំ អុំ អី ។

## មេរៀនទី ១០

> កាលបើបង្រៀន "អ" ពេញតួផ្សំនឹងស្រៈនិស្ស័យរួចហើយ គ្រូវលុបតួ (អ) ចេញ ដើម្បីឲ្យនៅតែស្រៈនិស្ស័យ ។ គ្រូត្រូវហ្វឹកហ្វឺនសិស្សឲ្យចេះអាន ចេះសរសេរ ស្រៈនិស្ស័យ ទាំងអស់ជាប្រាកដ ។

ា ិ ី ឹ ឺ ុ ូ ួ ើ

ឿ ៀ េ ែ ៃ ោ ៅ ុំ ំ

ាំ ះ ។ ុះ េះ ោះ ។

## មេរៀនទី ១១

ា ិ ី ឹ ឺ ុ ូ ួ ើ ឿ ៀ េ ែ ៃ ោ ៅ ុំ ំ ាំ ះ ។ ុះ េះ ោះ ។

# ក គ

កា កិ កី គឹ គឺ គុ គូ គួ កើ កឿ កៀ គេ គែ គៃ គោ កៅ កុំ គំ កាំ កះ ។ គុះ គេះ កោះ ។

គុ កា គើ កោ គួ កូ គៃ កៀ កែ គោ



គែ កៃ គា គៅ ។

កែះ កោ(រ) គ គះ កោះ

គេះ គះ ក កោះ គេះ គោះ

កៅ អី គែ គោ អាកោ ។

គា អាំ ក កូ(រ) អី ។ អាកែ កកែះគុ ។

អាកៅ កកេ(រ) អាគោ ។

## មេរៀនទី ១២

ា ិ ី ឹ ឺ ុ ូ ួ ើ ឿ ៀ េ ែ ៃ ោ ៅ ុំ ំ ាំ ះ ៗ ុះ េះ ោះ ៗ

# ប ហ

បា បិ បី ហឹ ហឺ ហុ ហូ បួ បើ បឿ បៀ ហេ ហែ ហៃ

បៅ ហុំ បំ បាំ បះ ៗ បុះ បេះ ហោះ ៗ



បើ ហា បូ ហំ បី ហើ បៀ ហោ បៅ ។

បោ(រ) ហូ(រ) បោះ ហៀ(រ) បេះ ហែ ហៃ

អាហា(រ) បប(រ) បះបោ(រ) បបូ(រ) ហោះ ។

បប(រ)ហៀ(រ) ។ តាកៅ ហៅអាតោ ។

# មេរៀនទី ១៣

ា ិ ី ឹ ឺ ុ ូ ួ ើ ឿ ៀ េ ែ ៃ ោ ៅ ុំ ំ ាំ ះ ៗ ុះ េះ ោះ ៗ

# ប ប៉

បាបិបីបឹបឺបុបូបួបើបឿបៀបេបែបៃបោបៅបុំបំបាំបះ ៗ បុះបេះបោះ ៗ



បុ ប៉ៅ បា ប៉ូ បេ

ប៉ុ បៅ ប៉ា បៃ បី បំ ប៉ោ

បែ ប៉ួ បាំ ប៉ែ ។

ប៉ោះ បោ(រ) ប៉ូ(រ)

បេះ បុះ ប៉ៅ កែ បំ កា(រ) ប(រ) បា ។

បី គូ បេះ ប(រ) បា ។ ចៅ កៅ បាំ ប៉ៅ កែ

បុះ ។ បៅបៃបាំបំការ ។ តាបឿបេះប៉ែបៅ ។

## មេរៀនទី ១៤

ា ិ ី ឹ ឺ ុ ូ ួ ើ ឿ ៀ េ ែ ៃ ោ ៅ ុំ ំ ាំ ះ ុះ េះ ោះ

# ដ ផ

ដា ផិ ដី ផឹ ដឺ ដុ ដូ ដួ ដើ ផឿ ផៀ ផេ ដែ ដៃ ដោ ដៅ ដុំ ដំ ដាំ ដេះៗ ដុះ ផេះ ដោះៗ



ដូ ដោ ដេ ដូ ដើ ដុ ដា ដោ ដៅ ដេ ដែ ដៀ ។

ដូ(រ) ដោះ ដុះ ដុំដី ដុំដែ ចុះផែ ដំបែ ដំបៅ ។

កុំដោះដៃ ។ ចែតុំដាំបប(រ) ។ ចីដាបោះដីបី

ដុំ ។ ចៅតោចាំផែ ។ ចៅតាដៃដើ(រ)តេះតះ ។

## មេរៀនទី ១៥

ា ិ ី ឹ ឺ ុ ូ ួ ើ ឿ ៀ េ ែ ៃ ោ ៅ ុំ ំ ាំ ះ ។ ុះ េះ ោះ ។

# ស ណ

សា សិ សី សឹ សឺ ណុ ណូ ណួ សើ សឿ សៀ សេ ណែ ណៃ ណោ ណៅ

សុំ សំ សាំ សះ ។ ណុះ សេះ ណោះ ។



សេ ណែ សុ ណាំ

សៀ ណា សួ ណៅ

សុំ ណី សោ ណើ ។

ដំណាំ សំដី បំណុះ សំបៃ សំណៅ សំដៅ

ដំណើ(រ) ស(រ)សៃ បំណី ស(រ)សើ(រ) សំណុំ ។

ជីសោស(រ)សេ(រ)សំណៅ ។ តាសំបេះដាំ

ដំណាំ ។ អាណាសុំបំណី ។ ជីណៃសួ(រ)អី ។

មេរៀនទី ១៦

ា ិ ី ឹ ឺ ុ ូ ួ ើ ឿ ៀ េ ែ ៃ ោ ៅ ុំ ំ ាំ ះ ។ ុះ េះ ោះ ។

# ឆ ខ ឡ

ឆា ខិ ខី ខឹ ខឺ ឡុ ឡូ ឡួ ឆើ ឆឿ ឆៀ ខេ ខែ ខៃ ឡោ ឡៅ ឆុំ ឆំ ឆាំ ឆះ ។ ឆុះ ខេះ ឡោះ ។

ឆែ ខំ ឆា ខា ឡៅ ឆោ ខាំ ឆាំ ឡូ ខោ ឡែ ។



កៅ ឡៅ ឡាំ សាំ កែ ខៃ

ឡូ ឡា ឆា ឆៅ ឡេះ ឡោះ

ខះក ពោះ ឡូ ឡែ ឡ ។

ចៅ សៅ ពោះ ឡូ ។ ចី តោ ដើ(រ) ឡែ ឡ

បី ខែ ។ ចែ ឡា ខំ ដេ(រ) ខោ ចៅ ឆាំ ។ ចៅ

សំ ខាំ ដៃ តា កៅ ។ កុំ ឆា ឆៅ តា អាំ ។

## មេរៀនទី ១៧ (សារឡើងវិញ)

ក ខ ប ឆ ដ ត ឋ ណ ប ផ ស ហ ឡ

ក កា ខិ ខី ចឹ ចឺ ធុ ធូ ដួ ដើ តឿ ថៀ ថេ

ណែ ណៃ បោ បៅ ផុំ ផំ សាំ សះ ។ ហុះ ឡេះ ឡោះ ។

កំបោ(រ) កំឡោះ ឆាំ ឆា ឆោឡោ បំបៅ

សស(រ) សសៀ(រ) សំដី សំឡី ហូ(រ)ហៃ ។



បៃសំបេះ សំបួ(រ)។ ខោចៅ តោឆេះ ។ បៃខាំសសោះអំបោះ ។ ចៅកែបេះ បៃ ។ ចៅតាអាំបេះកកែកក(រ) ។ ចីសៅសុំសំ-ឡកកូ(រ)បៃឆាំ។ចៅកែឡាំខំសំបៃសំណបីដុំ។

# មេរៀនទី ១៨

អ៊ អ៊ា អ៊ិ អ៊ី អ៊ឹ អ៊ឺ អ៊ុ អ៊ូ អ៊ួ អ៊ើ អ៊ឿ

អ៊ៀ អ៊េ អ៊ែ អ៊ៃ អ៊ោ អ៊ៅ អ៊ុំ អ៊ំ អ៊ាំ អ៊ះ ។

អ៊ិះ អ៊ុះ អ៊េះ អ៊ោះ ។

អ៊ូអ(រ) អ៊ូអា អ៊ូអែ អ៊ឹអ៊ះ ។

| |
|---|
| ឲ្យសិស្សអាន សរសេរឲ្យបានត្រឹមត្រូវល្អ រូបលុប (អ៊) ចេញ |

៊ ៊ា ៊ិ ៊ី ៊ឹ ៊ឺ ៊ុ ៊ូ ៊ួ ៊ើ ៊ឿ

៊ៀ ៊េ ៊ែ ៊ៃ ៊ោ ៊ៅ ៊ុំ ៊ំ ៊ាំ ៊ះ ។

៊ិះ ៊ុះ ៊េះ ៊ោះ ។

## មេរៀនទី ១៩

ា ិ ី ឹ ឺ ុ ូ ួ ើ ឿ ៀ េ ែ ៃ ោ ៅ ុំ ំ ាំ ះ ៗ ិះ ុះ េះ ោះ ៗ

# គ ភ

គា គិ គី គឹ គឺ គុ គូ គួ គើ គឿ គៀ គេ គែ គៃ គោ គៅ គុំ គំ គាំ គះ ៗ គិះ គុះ គេះ គោះ ៗ



គី ភា គួ គោ គឿ

ភី គុ គោ ភូ គេ ភើ

គូ ភៃ គុំ ភេ ។

គគី(រ) ភាសា គោបា សំភី គាថា សុភា ។

ចៅ ភុំ ចាំ គេ ។ ចី ឡា ចេះ បី ភា សា ។

គុំ ភ(រ) ចៅ គាំ ។ គេ ថា ចៅ ខាំ ចេះ គូ(រ) ភេ ។

## មេរៀនទី ២០

ា ិ ី ឹ ឺ ុ ូ ួ ើ ឿ ៀ េ ែ ៃ ោ ៅ ុំ ំ ាំ ះ ុះ េះ ោះ ។

# ព ញ

ពាពិពី ញឹញឺញុញូញួ ពើពឿពៀ ញេញែញៃញោញៅ ពុំពំពាំពះ ។
ពិះ ញុះ ពោះ ញោះ ។

ញាំ ពី ញើ ពា ញី ពើ ពួ ញោ ពូ ញុ
ពៃ ញោ ពៅ ញួ ពាំ ។

ពុះ ញុះ ពោះ ពួ(រ) ពពុះ សំពៅ ពូថៅ ពូកែ។



ចៅតាំគូ(រ)ញញួ(រ)។

តា ភេ ដាំ អំពៅ ។

ពូ សៅថែ ពពែ ញី

ពី(រ) ។ ថែ ពៅ ចេះ ពិ សា ប ប(រ) ពោះគោ ។

## មេរៀនទី ២១

ា ិ ី ឹ ឺ ុ ូ ួ ើ ឿ ៀ េ ែ ៃ ោ ៅ ុំ ំ ាំ ះ ។ ុះ េះ ោះ ។

# រ វ

រា រិ រី រឹ រឺ រុ រូ រួ រើ រឿ រៀ រេ រែ រៃ រោ រៅ រុំ រំ រាំ រះ ។ រិះ រុះ រេះ រោះ ។



រេ វៃ រោ វា រើ វៅ រួ វេ

រា វិ រុំ វូ វៃ វៀ រាំ ។

រុះ វះ រិះ វេះ វី វា បា រំពេ រុះ វើ រវៃ

របេះ ពីរោះ វេរា រកា រវៃ ។

ឋីភុំ ចេះ រាំ ។ តា ពៅ វះ ពោះគោ ។

ពពែ ញី ដើ(រ) វេរា ។ សំដីតូឆាំពីរោះ ។

បែ តាំ តូកែរវៃអំពោះ ។ គេ ខំ ដេ(រ) រវៃ ។

មេរៀនទី ២២

ា ិ ី ឹ ឺ ុ ូ ួ ើ ឿ ៀ េ ែ ៃ ោ ៅ ុំ ំ ាំ ះ ។ ិះ ុះ េះ ោះ ។

# ល ឈ

លាលិលីលឹលឺ ឈុឈូឈួ លើលឿលៀលេ ឈែឈៃឈោឈៅ លុំលំ

លាំលះ ។ ឈិះ ឈុះ លេះ លោះ ។



លូ ឈោ លឿ ឈុំ

លា ឈៀ លិ ឈឺ លៃ

ឈឿ លៀ ឈើ លោ ។

លោះ រលុះ លីលា រលំ លលា លលៃ ។

ពូឈុំលីឈើ ។ ថែតាំឈើពោះបីខែ ។

ចៅធាំលាតាភ ។ ថៅកែឈ(រ)លើកៅអី ។

កុំដើ(រ)ឈូធ(រ)លើដៃ ។

## មេរៀនទី ២៣

ា ិ ី ឹ ឺ ុ ូ ួ ើ ឿ ៀ េ ែ ៃ ោ ៅ ុំ ំ ាំ ះ ៗ ិះ ុះ េះ ោះ ៗ

# យ យ

យា យិ យី យឹ យឺ យុ យូ យួ យើ យឿ យៀ យេ យែ យៃ យោ យៅ យុំ យំ យាំ យះ ៗ

យិះ យុះ យេះ យោះ ៗ




យោ យុ

យួ យឺ យឹ

យោ យា យូ យើ យៅ យូ យាំ យី យុំ យំ ។

យូ(រ) តយា(រ) យីកេ យួ(រ) យី ហោ រយះ

យោ(រ) យៅ យីអើ សាលា យុំ ។

គេយុំ ទៅ រុំ ។ តា អាំ ចេះ រាំ យីកេ ។ ចីគូស(រ)

សេ(រ) យីហោ ។ ពូ ឈុំ ឈឺ អី ដើ(រ) យួ(រ) ដៃ ។

## មេរៀនទី ២៤

ា ិ ី ឹ ឺ ុ ូ ួ ើ ឿ ៀ េ ែ ៃ ោ ៅ ុំ ំ ាំ ះ ៗ ុះ េះ ោះ ៗ

# ម ធ

មាមិមី ធឹធឺធុធូធួ មើមឿមៀមេ ធែធៃធោធៅ មុំមំមាំមះ ៗ មិះធុះធេះមោះ ៗ



មើ ធំ មេ ធោ មៀ ធុ

មិ ធូ មា ធា មូ ធើ មាំ ។

មូ(រ) មមែ ធូលិ មីសួ

វិធី មមើ មមី(រ) មហោរី ។

មេធាវីនេះចេះបីភាសា ។ មេអំបៅនោះ

ហើ(រ)រេភ ។ តាបឿខំថែមេពពែ ។ ពូកុំ

ពិសាសំឡមីសួ ។ មេឃុំសៅហៅមេធួ ។

មេរៀនទី ២៥

ា ិ ី ឹ ឺ ុ ូ ួ ើ ឿ ៀ េ ែ ៃ ោ ៅ ុំ ំ ាំ ះ ៗ ិះ ុះ េះ ោះ ៗ

# ជ ឈ

ជាជិជី ឈិឈីឈុឈូឈួ ជើជឿជៀជេ ឈែឈៃឈោឈៅ ជុំជំជាំជះ ៗ ជិះជុះ ឈេះឈោះ ៗ



ជួ ឈោ ជាំ ឈូ ជោ

ឈៀ ជុ ឈា ជិ ឈឺ ជើ ឈួ ។

ជួ(រ) ឈា(រ) ជូ(រ) ជំងឺ

ជីតា រឈា ជីលា ឈេឈើ ។

គូលីជំរះដី ។ តាសោពូកែថែជំងឺ ។ ចៅខាំ

ជឿសំជីមាវ ។ ប៊ីទុំជិះសេះញី ។ ជីពោឈ(រ)

ឈេឈើលើដៃ ។ ជីតាចៅជុំឈា(រ)ជាមហា ។

## មេរៀនទី ២៦

ា ិ ី ឹ ឺ ុ ូ ួ ើ ឿ ៀ េ ែ ៃ ោ ៅ ុំ ំ ាំ ះ ៗ ុះ េះ ោះ ៗ

# ទ ន

ទា និ នី នឹ នឺ ទុ ទូ នួ នើ ទឿ ទៀ ទេ ទែ ទៃ នោ នៅ ទុំ ទំ ទាំ ទះ ៗ ទិះ នុះ ទេះ នោះ ៗ

ទេ នា ទៃ នូ ទុំ នាំ ទៅ នំ ទូ នៅ ទា ។

ទីទៃ នាវា ទំហំ នាគា ទំនេ(រ) ឆានា

ទទា នាទី នគ(រ) ទំពា នាឡិកា ទេវតា។



កុំ នាំវា ទៅ ទីនោះ ។

តា ពៅ ទៅ ឆា នា ដី ឆាំ។

ពូដា ទា(រ)នាឡិកា ពីចៅទុំ។ គេជិះរទេះ

តោ ទៅ ណា ។ ទីនេះ ពុំ ទំនេ(រ)ទេ ។

# មេរៀនទី ២៧

គ្រូយកតួអក្សរដែលសរសេរលើក្រដាសក្រាស់មកបង្ហាញសិស្សមួយម្ដង ៗ ហើយ សួរសិស្សថា : នេះអក្សរអី ? រួចគ្រូសរសេរតួអក្សរនោះត ៗ គ្នា ដូចខាងក្រោមនេះ គ្រូហ្វឹកហ្វឺនសិស្សឲ្យចេះអាន ចេះសរសេរតួអក្សរទាំងនេះជាប្រាកដ ។

| | | | | |
|---|---|---|---|---|
| ក | ខ | គ | ឃ | ង |
| ច | ឆ | ជ | ឈ | ញ |
| ដ | ឋ | ឌ | ឍ | ណ |
| ត | ថ | ទ | ធ | ន |
| ប | ផ | ព | ភ | ម |

យ រ ល វ ស ហ ឡ អ ។

មេរៀនទី ២៨

ា ិ ី ឹ ឺ ុ ូ ួ ើ ឿ ៀ េ ែ ៃ ោ ៅ ុំ ំ ាំ ះ ។ ុះ េះ ោះ ។

# ង៉ ញ៉ ន៉ ប៉ ម៉ យ៉ រ៉ ល៉ វ៉ ហ្វ៉

ង៉ា ញ៉ិ ញ៉ី ន៉ឹ ន៉ឺ ប៉ុ ប៉ូ ម៉ួ ម៉ើ យ៉ឿ រ៉េ វ៉ែ ល៉ៃ ល៉ោ រ៉ៅ ហ្វ៉ុំ ហ្វ៉ំ ហ្វ៉ាំ ហ្វ៉ះ ។

ម៉ុះ ញ៉េះ ង៉ោះ ។



ង៉េះ ង៉ោះ ញ៉េះ

ញ៉ោះ ញ៉ុំ ញ៉ើ

សេនា ប៉ុឆា ម៉ៃ

តាប៉ែ ប៉ីអ ម៉ឆែ មួម៉ៅ យ៉ាដាំ រយ៉ៃ បារី ដំរី

សាលាបាលី តាភៅ សាភា កាហ្វេ ។

ចែម៉ៃដើ(រ)ញ៉ាំញ៉ើ ។ ម៉ែដីម៉ៅមូ(រ)បារី ។

តាភៅយំពីភេះ ។ គេបោះខោរយ៉ៃទៅដី ។

មេរៀនទី ២៩

៊ា ៊ិ ៊ី ៊ឹ ៊ឺ ៊ុ ៊ូ ៊ួ ៊ើ ៊ឿ ៊ៀ ៊េ ៊ែ ៊ៃ ៊ោ ៊ៅ ៊ុំ ៊ំ ៊ាំ ៊ះ ៊ុះ ៊េះ ៊ោះ ។

# ប៊ ស៊ ហ៊

ប៊ា ប៊ិ ប៊ី ប៊ឹ ប៊ឺ ស៊ុ ស៊ូ ស៊ួ ស៊ើ ស៊ឿ ហ៊ៀ ហ៊េ ហ៊ែ ហ៊ៃ ហ៊ោ ហ៊ៅ អ៊ុំ អ៊ំ អ៊ាំ

អ៊ះ ។ ហ៊ិះ ស៊ុះ ប៊េះ អ៊ោះ ។



សា ប៊ូ ឈ(រ)

ហ៊ើភាស៊ីដំហ(រ)

តៅ ហ៊ូ ភ ហូ ហ៊ឺ ហា ។

តាប៊ូបេះតូ(រ)ភហូ ។ ប៊ីអ៊ឺដើ(រ)ហ៊ឺហា ។ ដីឡាំបេះស៊ីតៅហ៊ូ ។ ហ៊ាប៊ឺជាមេភាស៊ី នៅដីហែ ។ នៅទីនេះគេហ៊ៅអ៊ី ។ ចៅម៉ៅ ទា(រ)សាប៊ូប៊ីដុំ ។ នាភនេះជំរៅពី(រ)ដំហ(រ)។

## មេរៀនទី ៣០ (សាឡើងវិញ)



សុភាកុំស(រ)សេ(រ)ដីកាកោះ ។ ពូអាំដើ(រ)តែគោ ។ បែដាលោះសេះពីចៅកែសំ ។ ចៅឆាំទៅលាដីតាភា ។ ហ៊ាកៅពិសាបប(រ)ទា ។ គេស(រ)សើ(រ)ថាចៅឈុំបេះគូ(រ)រទេះ ។ នាភានោះចុះពីដីហែ ។ តាសំពូកែបែតតែញី ។ មេឃុំដុំរើសាលាបាលី ។ សារិកានេះបេះបីភាសា ។ ដីសៅលីពូចៅទៅចំកា(រ) ។ ចៅកែឈើបីខែ ។

## មេរៀនទី ៣១

> នៅក្រោមតួអក្សរនីមួយ ៗ ត្រូវថែមជើងដូចមានរបៀបតទៅនេះ ។ សូមបង្ហាញសិស្សឲ្យឃើញច្បាស់ របៀបដែលគេសរសេរជើងអក្សរ ហើយឲ្យសិស្សហាត់សរសេរ នៅលើក្ដារខៀន ឲ្យបានត្រឹមត្រូវ ។

ក្ក ខ្ខ គ្គ ឃ្ឃ ង្ង ច្ច ឆ្ឆ ជ្ជ ឈ្ឈ ញ្ញ

ដ្ដ ឋ្ឋ ឌ្ឌ ឍ្ឍ ណ្ណ ត្ត ថ្ថ ទ្ទ ធ្ធ ន្ន

ប្ប ផ្ផ ព្ព ភ្ភ ម្ម យ្យ រ្រ ល្ល វ្វ ស្ស ហ្ហ អ្អ ។

## មេរៀនទី ៣២

> បើសិស្សចេះអាន សរសេរតួអក្សរខាងលើនេះហើយ ព្រមទាំងជើងផង ត្រូវលុបតួអក្សរចេញ ឲ្យនៅតែជើង ។ សូមហ្វឹកហ្វឺនសិស្សឲ្យស្គាល់ ឲ្យចេះសរសេរជើងអក្សរនីមួយ ៗ ជាប្រាកដ ។

...្ក ...្ខ ...្គ ...្ឃ ...្ង ...្ច ...្ឆ ...្ជ ...្ឈ ...្ញ

...្ដ ...្ឋ ...្ឌ ...្ឍ ...្ណ ...្ត ...្ថ ...្ទ ...្ធ ...្ន

...្ប ...្ផ ...្ព ...្ភ ...្ម ...្យ ...្រ ...្ល ...្វ ...្ស ...្ហ ...្អ

---

ដ្ឋ = ឋ

# សេចក្ដីណែនាំ

សិស្សស្គាល់តួអក្សរ និងជើងអក្សរអស់ហើយ ។ ត្រូវយកជើងអក្សរមួយមកផ្ញើនឹងតួអក្សរមួយ បញ្ចូលសំឡេងគ្នាទៅ ហាក់ដូចជាមានព្យញ្ជនៈតែមួយ ឧបមាដូចជា (ក) ដាក់ជើង ( ្វ ) បានជា (ក្វ) ឲ្យអានថា (ក - ង៉) ។

ប៉ុន្តែត្រូវចាំថា ជើងអក្សរណាដែលសម្លាប់បាន ដូចជា "ង ញ ន ម យ រ ល វ" តែងតែដូលសម្លេងតាមតួលើ ឧបមាដូចជា "ន" ផ្ញើនឹង "ខ" បានជា "ខ្ន" (ន ទៅជា នឹ) ។

ក្រៅពី ៨ តួនេះ ទោះយកទៅផ្ញើនឹងតួណា ៗ ក្ដី វាទាញសំឡេងគេទៅតាមសភាពរបស់ខ្លួន ឧបមាដូចជា "ប" ផ្ញើនឹង "ម" នៅតែសំឡេង "ប" ដដែល (ម្ប) អានថា (ម - ប) ។

## របៀបបង្រៀនមើលផ្ញើជើង

១— ត្រូវសរសេរ "ក្វ ក្ដ ក្ន ក្យ ក្ម ក្រ ក្ល ក្ស ក្អ" នៅក្ដារខៀន ហើយឲ្យសិស្សអានម្នាក់ម្ដង មួយពួកម្ដង ។

២— ឲ្យសិស្សរកពាក្យណាដែលមានសំឡេង "ក្វ . . . . . ក្អ" ហើយសរសេរពាក្យនោះត ៗ គ្នា នៅលើក្ដារខៀន ដូចក្នុងមេរៀនដែលមានតទៅខាងមុខនេះ ។

៣— ឲ្យសិស្សអានពាក្យទាំងនោះម្នាក់ម្ដង មួយពួកម្ដង ។

# មេរៀនទី ៣៣

វ្វ ដ្ដ ន្ន ប្ប ម្ម ្រ ល្ល ស្ស អ្អ

## ក្វ ក្ដ ក្ន ក្ប ក្ម ក្រ ក្ល ក្ស ក្អ

ក្វ ក្វា ក្ដិ ក្ដី ក្នឹ ក្នឺ ក្បុ ក្បូ ក្បួ ក្មើ ក្មឿ ក្រៀ ក្រេ ក្លែ ក្លៃ ក្លោ ក្លៅ ក្សុំ ក្សំ ក្អាំ ក្អះ ។

ក្វេះ ក្វួ(រ) ក្ដា(រ) ក្ដៅ ក្បួ(រ) ក្បោះ ក្រគ(រ)

ក្រញាំ ក្រទីក្រទា ក្របៅ ក្រពះ ក្រយៅ ក្រមុំ

ក្រឡ ក្រឡៀ ក្រៃ ក្រៅ ក្លា ក្លើ ក្អី ក្អៃ ។



ចៅក្រិជំនុំជំរះក្ដី ។ ក្របីឈ(រ) ក្បែ(រ)គោ ។ បៃពៅក្រញីហ៊ាប៊ី ។ ប៊ីភុំជិះនាវាទៅក្របេះ ។ ក្លើហា ក្រៅពីសាតែសំឡក្ដៅ ។ ជីសៅ

កេះក្រម(រ)ដំបៅ ។ ពូឈុំដើ(រ)ក្រទីក្រទា ។

## មេរៀនទី ៣៤

ច្ច ញ្ញ ន្ន ម្ម យ្យ ល្ល វ្វ ស្ស ជ្ជ ទ្ទ ព្ព

# ខ្ច ខ្ញ ខ្ន ខ្ម ខ្យ ខ្ល ខ្វ ខ្ស ខ្ជ ខ្ទ ខ្ព

ខ្ច ខ្ចា ខ្ញិ ខ្ញី ខ្នឹ ខ្នឺ ខ្មុ ខ្មូ ខ្យួ ខ្យើ ខ្លឿ ខ្លៀ ខ្វេ ខ្វែ ខ្វៃ ខ្វោ ខ្សៅ ខ្សុំ ខ្ជំ ខ្ទាំ ខ្ពះ ។



ខ្ចី ខ្ចៅ ខ្ជី ខ្ជា

ខ្ញី ខ្ញុំ ខ្ញាំ ខ្ទុះ ខ្ទះ

ខ្នា(រ) ខ្នុ(រ) ខ្នោះ

ខ្មី ខ្មេះ ខ្មែ(រ) ខ្មៅ

ខ្លា ខ្លី ខ្លៅ ខ្លះ

ខ្វា(រ) ខ្វែះ ខ្វះ ខ្សែ ខ្សោះ ។

ដីមៅ ខ្ចី ខ្មៅ ដៃ បៅ សៅ ។ ខ្មែ(រ) បេះ ដាំ ខ្ញី ។ គេ ទៅ ខ្វា(រ) ក្រពើ ។ ខ្លា ទះ គោ ពូ ភេ ។ តា ពៅ លី ខ្នោះ ទៅ ណា ។ បៃ ឆាំ ពិ សា ខ្ចៅ ។ ដំ បៅ តា កែ ហូ(រ) ខ្ទុះ ។ កុំ ស(រ) សេ(រ) ខ្ជី ខ្ជា ។ ខ្ញុំ លោះ ខ្សែ ដៃ ពី គេ ។

## មេរៀនទី ៣៩

្ន ្ម ្រ ្ន ្ម ្ល ្វ

# គ្ន គ្ម គ្រ ឃ្ន ឃ្ម ឃ្ល ឃ្វ

គ្ន គ្នា គ្និ គ្នី គ្មឹ គ្មឺ គ្រុ គ្រូ គ្រួ ឃ្នើ ឃ្នឿ ឃ្នៀ ឃ្លេ ឃ្លែ ឃ្លៃ ឃ្លោ ឃ្លៅ

ឃ្វុំ ឃ្វំ ឃ្វាំ ឃ្វះ ។



គ្នឹ គ្នា គ្នេ(វ)

គ្រឺ គ្រាអេះ គ្រាក្រ

គ្រឹះ គ្រុះ គ្រួ គ្រែ

គ្រោះ គ្រិ គ្រាំ គ្រា ។

ឃ្នោះ ឃ្នុំ ឃ្លា ឃ្លេ ឃ្លៃ ឃ្មុំ សេះ ឃ្លាំ ចោ(វ) ខ្លា ឃ្នុំ។ ដឹមៅឈ(វ) ចាំគ្នឹគ្នាភា ។ ចៅឆាំសំពះលាគ្រួភា។ ខ្ញុំបុះពីលើគ្រែ ។ តាសំខ្ចីឃ្នោះបែផៃ ។ ឃ្នុំធំទំនៅក្បៀ(វ)បាំឆា ។ ពូឈុំបេះឃ្មុំសេះ ។ គ្រួខ្ញុំស(វ)សេ(វ)តែបីឃ្លា ។ គ្រាអេះខ្ញុំនៅឃ្លាំចោ(វ) ។

មេរៀនទី ៣៦

ប្យ ្រ ក្ក ង្ង ដ្ដ ន្ន ម្ម ល្ល អ គ្គ ព្ព

# ប្យ ប្រ

# ឆ្ក ឆ្ង ឆ្ដ ឆ្ន ឆ្ម ឆ្ល ឆ្វ ឆ្អ ឆ្គ ឆ្ព

ប្យ ប្យា ប្រិ ប្រី ឆ្កឹ ឆ្កឺ ឆ្ងុ ឆ្ងូ ឆ្ងួ ឆ្ដើ ឆ្នឿ ឆ្នៀ ឆ្មេ ឆ្មែ ឆ្លៃ ឆ្អោ ឆ្អៅ ឆ្គុំ ឆ្គំ ឆ្ពាំ ឆ្ពះ ។

ប្យា(រ) បោះ ប្យោះ ប្រមុះ ប្រវា ប្រឡោះ ប្រឡំ

ប្រុះ ប្រែះ ប្រោះ ឆ្កា ឆ្កើះ ឆ្កែ ឆ្គាំ ឆ្ដោ ឆ្នៃ ឆ្នាំ ឆ្ពោះ

ឆ្មា ឆ្លេឆ្លា ឆ្លុះ ឆ្អើ(រ) ឆ្អែះ ឆ្អៅ ។



តាកែបែ ប្យា(រ) ដំណាំ ។ ដីម៉ៅឆ្កើះខ្ចៅឆាឡិកា ។ ខ្ញុំ បាំ ឆ្នាំ ខ្ញុំគឺ ឆ្នាំបោះ ។ គេដើ(រ) ឆ្ពោះទៅបំកា(រ) ។ ឆ្កែតាប៊ូខាំ ឆ្មាបែសៅ ។ អាឆាំដើ(រ) ឆ្លេឆ្លា ។ នៅទីនេះឆ្អែះអី ។ កុំប្រឡំគំន(រ) ។

## មេរៀនទី ៣៧

្រ ្វ ្ង ្ន ្ម ្ល ្វ

# ជ្រ ជ្វ ឈ្ង ឈ្ន ឈ្ម ឈ្ល ឈ្វ

ជ្រ ជ្រា ជ្រិ ជ្វី ជ្វឹ ជ្វឺ ឈ្ងុ ឈ្ងូ ឈ្ងួ ឈ្នើ ឈ្នឿ ឈ្នៀ ឈ្មេ ឈ្មែ ឈ្មៃ

ឈ្លោ ឈ្លៅ ឈ្លុំ ឈ្វំ ឈ្វាំ ឈ្វះ។



ជ្រអោ ជ្រដំ ជ្រលិះ ជ្រិះ

ជ្រុះ ជ្រេ ជ្រែ ជ្រៃ ជ្រោះ

ជ្រៅ ជ្រឹ ជ្រិះ ជ្វា ជ្វាលា

ឈ្នះ ឈ្មោះ ឈ្លី ឈ្លោះ។

ខ្លា ឃ្មុំ គោះ ឈ(វ)

ជ្រអោ ។ នាឡិកា ខ្ញុំ ជ្រុះ

ខ្ទៅ ។ កុំនៅក្បែ(រ) ជ្រានេះ ។ ជ្រោះនោះជ្រៅ ។ ខ្មែ(រ)

ខ្លះបេះភាសា ផ្កាជ្រៅ ជ្រិះ ។ សេះខ្ញុំឈ្នះសេះខ្មៅបៅកែបី ។

ជីតាបៅមៅឈ្មោះអី? ។ កុំឈ្លោះគ្នានៅក្រៅសាលា ។

## មេរៀនទី ៣៨

្ទ ្យ ្ម ្រ ្ល ្វ ្អ

# ត្ទ ត្យ ត្ម ត្រ ត្ល ត្វ ត្អ

ត្ទ ត្ទា ត្ទិ ត្ទី ត្យឹ ត្យឺ ត្មុ ត្មូ ត្មួ ត្រើ ត្រឿ ត្រៀ ត្រេ ត្រែ ត្លៃ ត្លោ ត្លៅ ត្វុំ ត្វំ ត្អាំ ត្អះ។



ត្បា(រ) ត្មុះ ត្រជិំ ត្រឈៃ ត្រដ(រ) ត្រ-សុំ ត្រសេះ ត្រឡុំ ត្រា ត្រាជូ ត្រី ត្រេះត្រុះ ត្រៃ ត្រេះ ត្រិុ ត្រាំ សាត្រា ត្លៃ ត្វុំ ត្វា ត្អ ។

ជីខ្ទៅត្បា(រ)ប្រមុះ ។ តាសៅទៅផ្ទះត្រីឆ្ដោ ។ ហៅខាំត្រដ(រ)ដើ(រ)ទៅណា ។ បៃមៅយួ(រ)ត្រីឆ្អើ(រ) ។ មេឃុំបោះត្រាលើសំណៅ ។ ពូឈុំទៅខ្ទឹសាត្រាគេ បីខ្បែ ។ គ្រូភុំទៅត្រាំខ្ទា(រ) ។

## មេរៀនទី ៣៩

ក្ក ង្ង ន្ន ម្ម ល្ល វ្វ ព្ព

# ថ្ក ថ្ង ថ្ន ថ្ម ថ្ល ថ្វ ថ្ព

ថ្ក ថ្កា ថ្កិ ថ្កី ថ្ងឹ ថ្ងឺ ថ្នុ ថ្នូ ថ្នួ ថ្មើ ថ្មឿ ថ្មៀ ថ្លេ ថ្លែ ថ្លៃ ថ្វោ ថ្វៅ ថ្ពុំ ថ្ពំ ថ្ពាំ ថ្ពះ ។



ថ្ក(រ) ថ្ងូ(រ) ថ្ងៃ ថ្នេ(រ) ថ្នាំ ថ្មី ថ្មៃ ថ្លា ថ្លៃ ថ្លៃថ្នូ(រ) ថ្វីដៃ ថ្ងៃ យុថ្កា ។ ថី ម៉ែ ថ្ងូ(រ) ថា ឈឺ ប្រ មុះ ។ ថ្ងៃ សៅ(រ៍) ខ្ញុំ ទៅ ត្រិ ខ្នា(រ) ។ ថ្នាំ គ្រូ សៅ ពូកែ ។ តា ពៅ លឺ ថ្មី ទៅ ណា ? ។ ថ្នាំ ខ្មែ(រ) ក៏ ថ្លៃ ដែ(រ) ។ ការី ទា ជា សំឡ ថ្លៃ ថ្នូ(រ) ។ រទេះ ថ្មី ណៃ នៅ ថ្មី ។ ការ នេះ ជា ថ្វី ដៃ គ្រូ ខ្ញុំ ។ ថ្ងៃ នោះ បុះ ពី ក្រ-បេះ ។ គេ តុំ ដើ(រ) ទេ នៅ វេលា ថ្ងៃ ក្ដៅ ។

## មេរៀនទី ៤០

្រ ្វ ្ន ្ម ្យ ្ល ្វ

# ទ្រ ទ្វ ធ្វ ធ្ន ធ្ម ធ្យ ធ្ល ធ្វ

ទ្រ ទ្រា ទ្វិ ទ្វី ទ្វឹ ទ្វឺ ធ្នុ ធ្នូ ធ្នួ ធ្មើ ធ្មឿ ធ្មៀ ធ្យេ ធ្យែ ធ្យៃ ធ្លោ ធ្លៅ ធ្វុំ ធ្វំ ធ្វាំ ធ្វះ ។

ទ្រគោះ ទ្រនំ ទ្រហោ ទ្រូ ទ្រាំ ទ្រ ទ្វា(រ) ធ្នូ

ធ្មៃ ធ្លា ធ្មុះ ធ្នូ ធ្លៀ ធ្លុះ ធ្វើ ។



តាទៅទំលើទ្រនំ ។ ចៅកែទ្រហោយំ ។ តាពៅលីទ្រូទៅណា? ។

គេខំទ្រាំទ្រជំងឺជាយូ(រ)ថ្ងៃ ។ ទ្វា(រ)នេះធំ ។ ចៅមៅខ្ចីធ្នូពូខ្មៅ ។ ប៉ែសោរទៅខ្សែធ្មៃ ។ គេដើ(រ)ក្រោធ្លា ។ មេឃុំទៅធ្វើកា(រ) ។ ខោជីសំធ្មុះ ។ គេធ្វើធ្នើ(រ)លើទ្រូ ។

មេរៀនទី ៤១

្ដ ្រ ្ល

# ប្ដ ប្រ ប្ល

ប្ដ ប្តា ប្ដិ ប្រិ ប្រឹ ប្រឺ ប្លុ ប្លូ ប្លួ ប្ដើ ប្ដឿ ប្ដៀ ប្រេ ប្រែ ប្រៃ ប្លោ ប្លៅ ប្ដុំ ប្ដំ ប្ដាំ ប្ដះៗ



ប្ដី ប្ដូ(រ) ប្រកា(រ) ប្រខាំ ប្រគំ ប្រប៊ី ប្រឆេះ ប្រជុំ ប្រឈ្លោះ ប្រដៅ ប្រណី ប្រទះ ប្របេះ ប្រផិះ ប្រពៃ ប្រៃកាំ ប្រមា ប្រឡេះ ប្រឡៅក្អែ ប្រសើ(រ) ប្រហើ(រ) ប្លង្ហូ ។

បែធំទៅហៅប្ដី ។ ជីពោប្ដូ(រ)ខ្សែនាឡិកា ។ តាកែដើ(រ)ទៅប្រទះខ្លាឃ្មុំ ។ សេះប្រផិះឈ្នះសេះខ្មៅ ។ នៅទីនោះគេប្រជុំគ្នាធ្វើអី ។ សំឡនេះធុំប្រហើ(រ) ។

# មេរៀនទី ៤២

ក្ក ង្ង ច្ច ញ្ញ ដ្ដ ន្ន ល្ល ស្ស អ គ ខ្ខ

# ផ្ក ផ្ង ផ្ច ផ្ញ ផ្ដ ផ្ន ផ្ល ផ្ស ផ្អ ផ្គ ផ្ខ

ផ្ក ផ្កា ផ្ងិ ផ្ងី ផ្ចឹ ផ្ចឺ ផ្ញុ ផ្ញូ ផ្ដួ ផ្ដើ ផ្នឿ ផ្នៀ ផ្លេ ផ្លែ ផ្សៃ ផ្សោ ផ្អៅ ផ្អុំ ផ្គំ ផ្ខាំ ផ្ខះ ។

ផ្កា ផ្គូ ផ្គុំ ផ្ងំ ផ្ញើ ផ្ដា សា ផ្ដែ ផ្ដាំ ផ្ដៅ ផ្ដុំ ផ្ខឹ ផ្ខើ(រ) ផ្ខែ ផ្ខះ ផ្ទូ(រ)

ផ្លែ ផ្ដុ ផ្សា(រ) ផ្សំ ផ្គុ ផ្សែ ផ្សំ ផ្សាំ ផ្សះ ផ្សា ផ្អូ(រ) ផ្អេះ ៗ ។



ពៅ ឆាំបេះផ្កា បំប៉ា ប្រាំ។

តាភេ ផ្ដាំ ពៅ ឋា កុំ ប្រ

ឈ្លោះគ្នា ។ ពូសៅផ្ញើ

ត្រីឆ្ដោទៅថីជា ។ តាកែទៅបេះផ្លែផ្ដៅ ។ ពៅក្រិផ្សះផ្សា

គូក្ដី ។ បែសំពិសាសំឡប្រហើ(រ)ផ្ខី ។ ថីភុំឈឺពោះ

ផ្អេះៗ ។ គេផ្សំថ្នាំផ្សះដំបៅ ។

## មេរៀនទី ៤៣



ន្ន យ្យ ្រ ល្ល អ ង្ង ញ្ញ ញ ន្ន ល្ល

# ព្ន ព្យ ព្រ ព្ល ព្អ ភ្ង ភ្ញ ភ្ញ ភ្ន ភ្ល

ព្ន ព្នា ព្យិ ព្យ៍ ព្រឹ ព្រឺ ព្លុ ព្លូ ព្លួ ព្អើ ព្អឿ ភ្ងៀ ភ្ងេ ភ្ញែ ភ្ញៃ ភ្ងោ ភ្ងៅ ភ្នុំ ភ្នំ ភ្ងាំ ភ្ងះ ។

ព្នៃ ព្នៅ ព្យុះ ព្យួ(រ) កំព្រា ព្រី ព្រែ ព្រៃ ព្រោះ ព្រៅ

ព្រិ ព្រះ ព្អិះ ភ្ងា(រ) ភ្ញួ(រ) ភ្ងឺ ភ្នំ ភ្លា ភ្លើ ភ្លឺ ភ្លៅ ។

ពៅមៅបេះផ្លែព្នៅ ។ បៃពៅព្យួ(រ) ត្រីផ្អើ(រ) ក្បៀ(រ) ផ្ញើ(រ) ។ ពៅកំព្រាដេះប្ញ(រ)ឋាក្រ ។ ឋៅកែបឺនាំព្រៃពី ព្រៃនគ(រ) ។ តាកែភ្ញួ(រ)បំកា(រ) ។ គេបុះពីភ្នំក្រពើ ។ បីភ្នុំពិសាភ្លាត្រីផ្ដោ ។ ដីនាំដើ(រ)តេះតះព្រោះវាឈឺភ្លៅ ។

## មេរៀនទី ៤៤

ក្ក ខ្ខ ច្ច ដ្ដ ស្ប ហ្ហ អ ទ្ទ ជ្ឈ ញ ន្ន ន្ល យ្យ ្រ ល្ល

# ម្ក ម្ខ ម្ច ម្ដ ម្ប ម្ហ ម្អ

# ម្ទ ម្ឈ ម្ធ ម្ព ម្ន ម្យ ម្រ ម្ល

ម្ក ម្កា ម្ខិ ម្ខី ម្ចឹ ម្ចឺ ម្ដុ ម្ដូ ម្បួ ម្ហើ ម្អឿ ម្ទៀ ម្ឈេ ម្ទែ ម្នៃ ម្នោ ម្យៅ ម្រុំ ម្រំ ម្ទាំ ម្ទះ ៗ

ម្ជូ(រ) ម៉្រៃម្រិ ម្នឹម្នា ម្នោ ម្នុះ ម្រិ ម្រះព្រៅ ម្លិះ ម្លូ

ម៉្លេះ ម៉្លោះ ម្សៅ ម្ហេះៗ ។



ប៊ីជាពិសាសំឡម្ជូ(រ)ត្រី ប្រា ។ តាកែម្នឹម្នាទៅផ្ទះ ។ ពូឈុំដាំផ្កាម្លិះ ។ បៃពៅឈឺអីយូ(រ)ម៉្លេះ ។ ហ៊ាកៅឈ្លីម្សៅធ្វើនំប៉ៅ ។ នៅទីនេះជុំអ្វីម្ហេះៗ ។ អាឆាំទៅបេះម្រះព្រៅ ។ មាខ្ញុំធ្វើកា(រ) នៅម្លូព្រៃ ។

## មេរៀនទី ៤៧

្ខ ្ប ្ហ ្អ ្គ ្ង ្ព ្ម ្វ

# ល្ខ ល្ប ល្ហ ល្អ

# ល្គ ល្ង ល្ព ល្ម ល្វ

ល្ខ ល្ខា ល្បិ ល្បី ល្ហឹ ល្ហឺ ល្អុ ល្អូ ល្អួ ល្គើ ល្គឿ ល្ងៀ ល្ងេ ល្ពែ ល្ពៃ ល្មោ

ល្មៅ ល្ងុំ ល្ងំ ល្ងាំ ល្ងះ ។



ល្ងី ល្ងើ ល្បី ល្បះ

ល្ពៅ ល្មី ល្មើ ល្មៃ ល្វា

ល្វៃ ល្ហៃ ល្អី ល្អះ ។

ពៅសៅឈើទៅជាល្ងីល្ងើ ។ បែខាំផ្ញើល្ពៅទៅជីតា ។

ត្រីប្រាស៊ីផ្លែល្វា ។ បីៗល្ហែតែថ្ងៃសៅរ៍ ។ តាកែបេះ

ផ្ងើល្អីល្អៗ ។ ឃុំគ្រូសំល្បីជាយូរឆ្នាំ ។ គេដាំល្ងនៅ

ក្បែរភ្នំ ។ សំដីបីគូពុំល្អះសោះ ។ ផ្លែល្វាល្អតែក្រៅទេ ។

## មេរៀនទី ៤៦

្ក ្ង ្ញ ្ដ ្ន ្ប ្ម ្រ ្ល ្វ ្អ ្គ ្ខ ្ព

# ស្ក ស្ង ស្ញ ស្ដ ស្ន ស្ប ស្ម

# ស្រ ស្ល ស្វ ស្អ ស្គ ស្ខ ស្ព

ស្ក ស្កា ស្ងិ ស្ងី ស្វឹ ស្វឺ ស្កុ ស្កូ ស្អួ ស្នើ ស្បឿ ស្បៀ ស្មេ ស្រែ ស្រៃ ស្ងោ



ស្ងៅ ស្អុំ ស្ដំ ស្ខាំ ស្ពះ ។

ស្កា(វ) ស្កាំ ស្គ(វ)

ស្ងោ(វ) ស្វៃ ស្ដី ស្ដៅ ស្ខុះ

ស្ខោះ ស្នា ស្នោ ស្បៃ ស្ពឺ ស្ពៃ ស្មា ស្មៅ ស្រកា ស្រគំ ស្រងែ

ស្រណោះ ស្រទំ ស្រឡៅ ស្រី ស្រែ ស្លា ស្លែ ស្វា ស្អុះ ស្អ ។

ដឹ ម្លិះ ស្ងោ(វ) ស្នោ ។ បៅ កំព្រា នេះ ដំបៅ ស្វៃ ។

គេ ទៅ បេះ ផ្កា ស្ដៅ ។ បែ ខាំ ស្ខេ ល្ង ។ ស្រី ក្រមុំ នេះ ផ្ញើ

ធំ ផ្កា ស្នោ ។ តាកែ ពិសា ស្ពៃ ស្ងោ(វ) ។ ក្របី ស៊ី ស្មៅ ខ្ចី ។

## មេរៀនទី ៤៧ (សារឡើងវិញ)



ពូម៉ាខំភ្ជួ(រ) ស្រែ ។ ជីខ្មៅទៅ បេះផ្លែក្របៅ ។ ក្របីនោះស៊ីស្មៅខ្ចី ។ ខ្ញុំខ្ចីសាត្រាគេបីខ្សែ ។ បៃព្រិ ស្ងោ(រ)ត្រីឆ្តោ ។ សុភាផ្សះផ្សាគូក្ដី ។ ថ្ងៃនេះគេផ្លុំត្រែ ធ្វើអ្វី ។ គេបួ(រ)ថាឆ្នាំនេះត្រីថ្លៃ ។ ខ្លាឃ្មុំនេះខ្មៅ ។ តា ជាឆ្កាព្រៃធ្វើបំកា(រ) ។ ផ្កានេះបេះភាសាខ្មែ(រ)ជ្រោជ្រះ ។ ហៅកែសំផ្ញើម្សៅជ្រៃទៅក្របេះ ។ ស្រីៗនាំគ្នាទៅបេះ ផ្កាស្នោ ។ ផ្កែប៊ីភុំឈ្មោះអាម្លិះ ។ គ្រូខ្ញុំប្រដៅថាកុំ ប្រឈ្លោះគ្នា ។ គ្រែស្រឡៅនេះធ្វើពីត្រាំខ្ន(រ) ។

## មេរៀនទី ៤៨

# អង អង់ អាង អាំង អ៊ង អ៊ង់ អ៊ាង អ៊ាំង

កង កង់ ខាង គង គង់ ឃាំង បង បាំង ឆុង ជង់ ឈោង ញាំង ដ្លង តុង ឋាំង ទុង ឍាង បង់ ញុំង ឌង់ ពាង ឡុំង ។

ក្នុង ក្មេង ខ្យង ខ្លំង គ្រឿង ឃ្នាង ឃ្លង់ ប្យាំង ឆ្លំង ជ្រុង ឈ្នាង ត្បូង ត្រែង ប្នង ឋ្លាង ទ្រុង ធ្យូង ប្ដឹង ប្រែង ផ្អៀង ផ្សែង ភ្លើង ម្ដង ល្បែង ល្វង់ ស្នែង ស្អាង ។



កី កង់ ជិះ កង់ ទៅ លេង កំពង់ឃ្លាំង ។ គេលើប្នងទៅ ដង ត្រី ក្នុង បឹង ។ ឆាង តេង ផ្អៀង ផ្អង នៅ ខាង ត្បូង ជើង តាំង ។ មឹង ហោង ខឹង ឆឹង បង ។ ព្យូ បេង ប្រ ឡុង ធ្វើ ប្លង់ តុង ។ គេ ក្រែង ភ្លើង ផ្សែង ។ បង ខ្ញុំ បង់ ពិ សា នំ បាំង ។

# មេរៀនទី ៤៩

អញ អញ់ អាញ អាញ់ អ៊ញ អ៊ញ់ អ៊ាញ អ៊ាញ់

កាញ់ យើញ បាញ់ បេញ ជួញ ដេញ ទិញ ធុញ

បាញ់ ពេញ រួញ វិញ សាញ សំឡាញ់ បាញ់ កាញ់ ។

ក្រាញ ក្រាញ់ ខ្នាញ់ ខ្លាញ់ ប្រាញ ឆ្ងាញ់ ជ្រួញ

ឈ្លួញ ត្បាញ ត្សួញ ធ្មេញ ផ្អាញ់ ព្រួញ ភ្ញើញ ម្រេញ

ម្សាញ់ ស្មោញ ក្រញាញ់ ប្រដេញ សំណាញ់ ស្រឡាញ់



គេទិញខ្លាញ់ត្រី

ពីក្រុងភ្នំពេញ។

សំឡាញ់ បីបងត្សួញ ហាឈើធ្មេញ ។ សំពៅនេះបេញទៅ

ព្រែកគ(រ)វិញ ។ ខ្ញុំឃើញត្រីឆ្តោប្រដេញគ្នា ។ ពូក្រាញ់

ទៅបង់សំណាញ់ ។ ឈ្លួញនេះជួញបំណោញក្នុងផ្ទ៍

ម្សាញ់ ។ បីម៉ាញទិញខោឡាញ់ប្តី ។

## មេរៀនទី ៤០

អន អណ អន់ អាន អាន់

អ៊ិន អ៊ិន់ អ៊ាន អ៊ាណ អ៊ាន់

កាន់ ខាន គុណ ឃុន ចាន ឆាន់ ជាន់ ឈាន ជាន ណែន តាន់ ទៀន ទាន ទាន់ ធុន បែន ពាន ពាន់ មាន់។

ក្វាន ក្ដាន់ ខ្លួន ខ្វិន គ្មាន គ្រុន ប្រើន ឆ្អិន ឈ្មាន់ ប្លែន ទ្រាន់ ប្រាណ ប្លន់ ផ្លួន ព្រាន ភ្មែន ស្ដាន ស្ដាន់ ស្មៀន ស្វាន។



បងហៅកែសានទៅ បាញ់ក្ដាន់បានបួន។ ទា ហាន សន គ្រុន បាញ់ ពី ប៉ៃ លិន ។

ហៅ(វ) ប្លន់ តា ម៉ាន់ នៅ ស្គន់ ។ យើង លាង ខ្លួន ប្រាណ នឹង សាប៊ូ ។ ប៉ៃ យ៉ាន់ បាន សែន ព្រេន ពី ខែ មុន ។ គេ មិន ហ៊ាន បង ក្បួន នៅ ក្បែ(វ) ស្ដាន ។ ពង មាន់ នេះ មិន ទាន់ ឆ្អិន ។

មេរៀនទី ៥១

## អម អាម អ៊ម អ៊ាម

កម គោម បាម ញ ញិម ដើម តាម ទា ទឹម តោម
បៀម ផើម ពាម មើម យាម រើម លោម សៀម ហើម ។
ក្ដាម ក្រៀម ក្រោម ក្អម ខ្ទម ខ្ទឹម ខ្តើម ខ្លឹម ប្យាម
ប្រម ផ្អើម ត្រឹម ថ្គាម ថ្លើម ទ្រោម ធ្នឹម ប្លម ផ្ដើម ផ្អូម ផ្អែម
ព្រម ភ្លាម ម្រាម ម្អម ល្មម ស្គម ស្នាម ស្រោម ។



តាសោម សង់ ខ្ទម នៅ ក្រោម ដើម ក្រឡាញ់ ។ សំឡ បៃ តែម ផ្អូម ។ ជី ភេម បាំ មេ រៀន រា ភ្លាម ។ ស្មៀន សែម មិន បេះ នៅ ស្មៀម ។ នាង ពេន ថ្នម ប្អូន ពៅ ។ ជើង ពាន ស្តាត់ នេះ ដុះ ស្នឹម ។ ស្រោម ជើង នេះ ល្មម នឹង បី ឡម ។

# មេរៀនទី ៥២

អក=អខ=អឃ=អគ អក់ អាក=អាគ អាក់

អ៊ក=អ៊ខ=អ៊ឃ=អ៊គ អ៊ក់ អ៊ាក=អ៊ាគ អ៊ាក់



ខាក គោគ ឆោក ចាក ចាក់ ឆែក

ដុក ញាក់ ដែក តក់ បោក ទាក់ នាគ

ពួក ភាគ មុខ មេឃ រោគ សុខ ។

អ្នក=នាក់ ក្អោក ក្អៀក ក្អែក ខ្ជាក់ ខ្ទែក

បួក ឆ្កក ជ្រួក ឈ្លក់ ត្បក ប្ដុក ឆ្លាក់ ប្រាក់ ផ្គាក់ ផ្អក

ព្រែក ភ្នែក ម្នាក់ ល្បើក ល្អក់ ស្កក ស្នុក ស្បែក ស្លៀក ។

តា ម៉ក់ យក បួក ទៅ ចាក់ ត្រី ឆ្ដោ ។ ស្អែក ចី ចុក ភ្ញាក់ ពី ព្រឹក ទៅ ព្រែក កក់ ។ ក្មេង ណា ស្មោក គ្រោគ ច្រើន មាន រោគ ។ បែ សុក ភ្លក់ នំ គ្រក់ ។ ក្អែក ចុះ ទៅ ផឹក ទឹក ប្ដុក ។ ពួក នេះ ស្លៀក ពាក់ ប្លែក ពី គេ ។ អ្នក ស្រុក រែក ឃ្លោក ទៅ លក់ ។ ខ្ញុំ ស្រក់ ទឹក ភ្នែក ស្រោក ។

## មេរៀនទី ៥៣

អត = អដ = អថ = អទ = អឍ អត់ អាត អាត់

អ៊ត = អ៊ដ = អ៊ថ = អ៊ទ = អ៊ឍ អ៊ត់ អ៊ាត អ៊ាត់



កាត កាត់ ខាត ខាត់ គាត់

ឃាត់ ងៀត ចាត់ ចោទ ឆោត

ជាត់ ដោត ទាត់ បាត់ បាទ

ពោត ភេទ មាឍ ប្រាកដ ។

ក្ដាត ក្អាត់ ខ្ចាត់ ខ្ចិត ឃ្លាត

ប្រាត់ ប្រូត ឆ្នោត ឆ្អែត ឈ្ងុត ត្នោត ត្មាត ទ្រុឌ ប្រិត ប្លាត

ផ្ចិត ផ្សិត ព្រាត ភ្លាត់ ល្បាត ល្មុត ស្ងួត ស្នៀត ស្អាត

ស្បថ សមុទ្រ គ្រុឌ ។

ត្មាតនេះស៊ីមិនទាន់ឆ្អែត ។ គេដាំដើមត្នោតជិតមាត់សមុទ្រ ។ ត្រីស្លាតមានជាតិជាងត្រីឃ្លាត ។ បីម៉ែតឆ្លៀតផ្ញើបំណោទ ។ ពូឈុំស្បថលែងទិញឆ្នោតទៀត ។ នាងគាតហែកសំពត់បីហាត់ខ្នាត ។ គេដើ(រ)កាត់ព្រៃស្ងាត់ ។

មេរៀនទី ៤៨

អប=អផ អាប=អាផ អប់ អាប់

អ៊ប=អ៊ផ អ៊ាប=អ៊ាផ អ៊ប់ អ៊ាប់

កាប កាប់ ខូប គេប បុប ញេប ដាប ដាប់
តូប ទាប បី បាប់ ពូជ មុជ រោប ហាជ លួប
វៀប សាប សាប់ ហួប ។
ក្ខប ក្សាប់ ក្រូប ក្រ
បួប ខ្ជប ខ្មេប ខ្លាប ត្រេប
ឃ្លៀប ឃ្វិប ប្រាប់ ឈ្លេប ត្រាប ផ្តេប ឆ្មេប ប្រាជ្ញ ភ្លេប
ម្ដេប ម្រេប ល្វាប ល្អប ស្ដេប ស្នាប ស្រួប ស្អូប ។



គេ បាប ទឹក និង ស្នាប ។ បែ ទូប ភ្លេប ស្រោប ដំណាំ ។
ល្វាប នេះ បង ខ្ញុំ ទៅ បេះ ក្រូប ឃ្វិប ។ ជី ទ្លាប ឈ្លេប ស្រ
មោប ។ អាម៉ាប មិន នៅ ទី នេះ ព្រោះ វា ខ្លាប ឃ្មុំ ទិប ។
បូ(វ) កុំ លួប ក្ខប គេ ។ ហេតុ ម្ដេប បាន ជា នាង ក្ដិប
ប្អូន ។ កុំ កាប់ ពោត នោះ គេ ទុក ធ្វើ ពូជ ។

## មេរៀនទី ៥៥

អប=អព=អភ អប់ អាប អាប់

អ៊ប=អ៊ព=អ៊ភ អ៊ប់ អ៊ាប អ៊ាប់

កាប កាប់ ខាប ខាប់ គាប ងាប់ ចាប ចាប់ ឆាប ឆាប់ ជួប ធូប បាប ផាប់ ពៀប ភាព រាប់ លោភ ។

ក្ដិប ក្អែប ខ្ទប់ ខ្សឹប គ្រប់ ឃ្នាប ប្យាប់ ឆ្អាប ជ្រាប ត្រប់ ថ្កៀប ទ្រាប ធ្នាប់ ធ្លាប់ ប្រាប់ ផ្គាប់ ផ្អាប់ ព្រាប ម្ហូប ល្យប ស្វាប ស្នប់ ស្រោប ស្លាប ។



ប្រអប់ស៊ីវិឡាតនេះគ្មាន គ្រប ។ អ្នក ធ្នូប ចាប់ យក លាជ បី ក្ដាប់ ។ ទា បាន ឈ(រ) ត្រៀប ត្រា ក្នុង ម្លប់ ។ ពូ ព្រាប លេប ថ្នាំ គ្រុន ពី(រ) គ្រាប់ ។ គេ ខ្សឹប ប្រាប់ ខ្ញុំ ថា តា ក្លែប ស្លាប់ ។ អ្នក បំ កា(រ) ខ្ទប់ ម្ហូប ទៅ បរិភោគ ។ យើង ធ្លាប់ ខ្លាប ប្យាប់ ទំលាប់ ។

មេរៀនទី ៥៦

# អយ អាយ អ៊ិយ អ៊ីយ



កើយ គុយ ង៉ាយ បាយ ឆាយ ជួយ បំណាយ ទីទុយ បុភាយ ពពាយ ឆាយ ភូឈួយ មួយរយ រលួយ ហើយ ឡើយ ។

ក្លាយ ខ្ចាយ ខ្មាយ ខ្សាយ ឆ្ងាយ ឆ្លើយ ជ្រាយ ជ្រោយ ឈ្លើយ ឈ្មើយ ត្រួយ ហ្វាយ ឆ្លាយ ប្រាយ ផ្កាយ ផ្សាយ ព្រួយ ល្បោយ ល្វើយ ស្ពាយ ស្រួយ ។

យាយប្រាក់ស្រាយសំពាយ ។ ផ្ទះមេគយនៅក្រោយផ្ទះលោកភូឈួយ ។ ខ្អួយពួននៅក្រោមខ្នើយ ។ បីគួយព្រួយព្រោះក្អួយគាត់ឈឺ ។ ខ្ញុំស្តាយដោយពុំបានទៅស្វាយរៀងជាមួយនឹងម្តាយខ្ញុំ ។ លោកបៅហ្វាយបាយលុយមិនស្តាយសោះ ។

មេរៀនទី ៥៧

# អរ អារ អ៊រ អ៊ារ



កៃរ ខៀរ គារ បែរ ឆេរ ឆារ ដារ ជំទារ ថៃរ បារ ដារ រៀរ ឈារ សារម៉ារ ហោរ ហារ ឡៀរ អារ ។

ក្រែរ ខ្វារ ខ្វែរ ប្រារ ជ្រារ ត្រារ ត្រូរ ប្តូរ ប្រារ ផ្ទូរ ផ្អារ ព្រារ ផ្អៀរ ភ្លារ ស្កូរ ស្បូរ ស្រូរ ស្រៀរ ប្រជៀរ សារ ក្ដោង ។

តា ព្រាប ដក ដារ ស ផ្ទារ ។ នៅ ស្រុក ឈារ គេ ដាំ ដើម សារម៉ារ ជាច្រើន ។ យាយ កៃរ ពាក់ ការ តាំង ពី ក្មេង ។ គេ ផ្ទុក បារ ស្រូវ ក្នុង ទូក ថ្វៃ ។ ពូ ខៀរ ដើ(រ) តាម ផ្ទូរ រទេះ ទៅ ភូមិ ស្រយូរ ។ ជី ពីរ ពាក់ អាវ មិន ដាក់ ឡេវ ។ ដំទារ ភ្ញុំ ភ្ញាក់ មុន មាន់ រងារ

## មេរៀនទី ៥៤

*អល អល អាល អាល់ អ៊ិល អ៊ិល់ អ៊ាល អ៊ាល់*

កាល កាល់ ខែល គាល់ បាល់ ជួល ដោល ទាល ទាល់ ធិល បោល ពេល មើល យោល រៀល វាល វាល់ ហាល ។

ក្រាល ខ្ជិល ខ្វល ខ្យល់ ឃ្វាល ប្រាល ផ្កៀល ឆ្វើល ឆ្វែល ជ្រុល ឈ្មោល ថ្មាល ទ្រាល ផ្ដោល ផ្អើល ព្រាល ព្រើល ភ្ជល់ ម្ជុល ស្គាល់ ស្ទួល ស្រាល ។



យើង ត្រូវ ជំរះ ក្អែល រាល់ ថ្ងៃ ពីក្បាល រហូត ដល់ ចុងជើង។ លោកគ្រូ ខ្វល់ ព្រោះ ជី ប៉ុល វា ខ្ជិល ។ យាយ កែវ ពិសា ត្រាវ ទាល់តែស្កល់ ។ អ្នកស្រែ ខ្លះ មិន ដែល ស្គាល់ ត្រី ព្រួល ។ តា ក្រៀល ស៊ី ឈ្នួល ឃ្វាល ពពែ ។ ពូ ព្រិល ដេញ គោ ឈ្មោល ចូល ក្រោល ។ ផ្ដិល នេះ ស្រាល ស្តើក ។

## មេរៀនទី ៥៩

# អស អស់ អាស អាស់

# អ៊ស អ៊ស់ អ៊ាស អ៊ាស់

កោស ខុស បាស បាស់ ដួស ឈូស ញើស
ដួស ណាស់ ទោស បួស ពិស ពស់ មាស រើស
លៀស វាស វាស់ សិស្ស ហួស ។



ក្រាស ក្លស់ ខ្ទាស់ ខ្មោស
ខ្នាស ប្ញាស់ ប្រាស ឆ្មាស
ឆ្លាស់ ជ្រើស ឈ្ងួស ត្រួស
ហ្វាស ប្លស់ ទ្រើស ធ្មស់ ប្រាស ផ្លាស់ ព្រួស ភ្នាស់ ម្នួស
ល្មើស ស្រាស់ ក្រដាស អំពោស រនាស់ ។

បីរស់ សរសេរ លើ ក្រដាស ក្រាស់ ។ យាយឡាប កោស ដូងនឹងខ្មោស ។ តាលៀស មិន និយាយ ផ្ដេស ផ្ដាស ទេ ។ នាងសយ ឆ្លើយ ប្ញាស់ ណាស់ ។ គេបាច់ ត្រីរ៉ស់ ទៅ ក្នុង ស្រះ ។ ម្ដាយ ខ្ញុំ ជ្រើស រើស យកតែ ម្នួស ស្រស់ ។

## មេរៀនទី ៦០

| |
|---|
| ពាក្យប្រកបនឹង (រ) តាមទំនងហាក់ដូចជាគ្មាន (រ) ទេ តែតាមអក្ខរាវិរុទ្ធ ពាក្យខ្លះត្រូវតែដាក់ (រ) ពីមុខ |



បៃសៅ យួរ ត្រីផ្អើរ មក ពី ផ្សារ ។ នៅ សាលារៀន គ្រូតែ រៀន គូរ គំនូរ ពីរ ដង ក្នុង មួយ អាទិត្យ ។ តាកែ ដើរ ក្នុង ប្សារ ឃ្លាំ មើល ឆ្មា បា ។ ប៊ីមៅ កាន់ ការ ងារ នេះ យូរ ហើយ ។ គេ រៀប ក្មេង ឲ្យ ឈរ ជា ពីរ ជួរ នៅ ក្បែរ សាលា ។ ទា មិន ប៉ះ ការ ពារ កូន វា ទេ ។ ម្ដាយ ខ្ញុំ ពិ សា ពោត ស្ងោរ ជា មួយ នឹង ស្ករ ស ។ លោក គ្រូ សរ សេរ ពាក្យ សួរ នៅ លើ ក្ដារ ខៀន ។

ភរ នៅ ហោរ បោរ នៅ ដាង ។

---

អាទិត្យ (ម. ជ. អា-ទិត)

## មេរៀនទី ៦១ (ស្រៈសំស្រ្កឹតឬបាលី)

ឥ ឦ ឧ ឩ ឫ ឬ ឭ ឮ ឯ ឰ ឱ ឳ



ឥត ឥសី ឥឡូវ ឦសាន ឧកញ៉ា
ឧដុង្គ ឧត្តរ ឧបមា ឧបាយ ឪទឹង
ឪពុក ឪម៉ាល់ ឪឡ ឪឡឹក ឫកពា
ឫស្សី ឬទេ រឭក ឯក ឯង ឯកឧត្តម
ឱប ឱ្យ=ឲ្យ ឱកាស តាំងឱ ។

ខ្ញុំឮឪឡយំនៅទិសឦសាន ។ លោកតាឧកឥត មានឱកាសទៅឧដុង្គសោះ ។ ឧកញ៉ាឪឲ្យទៅទិញឃ្មុំឥសីផ្សំស្រេច ។ ឪម៉ាល់ទិបក្បាលដីឯក ។ នៅប្រទេសខ្មែរគេដាំឪឡឹកគ្រប់ដំបន់ ។ ឧបាសកសែមទៅដឹកទំពាំងឫស្សី ។ ឯងរឭកឪពុកឬទេ ។

---

ឧត្តរ (ម. ថ. អុត-ដរ) ឫស្សី (ម. ថ. ឫស-សី) ឧត្តម (ម. ថ. អ៊ុត-ដំ)

## មេរៀនទី ៦២ (ពាក្យពីរព្យាង្គតម្រួត)

កង្កែប (កង់ កែប) បង្ខាត (បង់-ខាត) អង្គុយ (អង់-គុយ) សង្ឃឹម (សង់-ឃឹម) បិញ្ចើម (បិញ-ចើម) ជញ្ជាំង (ជញ់-ជាំង) បញ្ញើ (ប័ញ-ញើ) អណ្ដើក (អណ់-ដើក) ប៉ុន្តែ (ប៉ុន-តែ) បន្ថែម (បន់-ថែម) កន្ទេល (កន់-ទេល) ដម្បូល=ដំបូល ទម្លាប់=ទំលាប់ បង្រៀន (បង-រៀន) ពន្យល់ (ពន់-យល់) ទន្សាយ (ទន់-សាយ) ជង្រុក (ជង់-រុក) បង្វិល (បង-វិល) បង្ហាត់ (បង់-ហាត់) បង្អែម (បង់-អែម) ។



គេនាំគ្នាជញ្ជូនបង្កង់ដាក់ក្រោមផ្ទះ ។ ជង្ខៅ មៅ បង្ខំកូនឲ្យរៀនមេទន្ទេញ ។ តាពេញស្ពាយសម្ពាយដើរកាត់មុខបន្ទាយ ។ ម្ដាយខ្ញុំដាក់បង្កៀងលើកន្ទេលផ្ដៅ ។ បែសំទៅទិញបង្កងមកធ្វើបង្ហាន់លោក ។ លោកគ្រូបង្គាប់ចៅកៅឲ្យអង្គុយជិតបង្អួច ។

# ភាគទី ២

## ១– សាលារៀនខ្ញុំ

សាលារៀនខ្ញុំសង់នៅកណ្ដាលទីធ្លាមួយធំ មានដាំដើមឈើ



ព័ទ្ធជុំវិញជារបង ។ នៅខាងមុខសាលាមានសួនច្បារពីរដ៏មានផ្កា មានពណ៌ ស ស៊ីជំពូ លឿង ស្វាយ ចម្រុះគ្នា ។ សាលានោះ សង់អំពីឈើ ប្រក់ក្បឿង មានកន្លែងរៀនបីធំទូលាយ ។ កន្លែងរៀននីមួយ ៗ មានទ្វារនឹងបង្អួចសម្រាប់ឲ្យខ្យល់នឹងពន្លឺចេញចូលបានស្រួល ។

សាលារៀនខ្ញុំសមណាស់ ហើយល្អជាងផ្ទះឯទៀតទាំងអស់ដែលនៅក្នុងភូមិខ្ញុំ ។

---

ព័ទ្ធ (ម ឋ. ព័ត) ។ ពណ៌ (ម.ឋ. ព័រ) ។



## ២– ពេលចូលរៀន

ម៉ោងប្រាំបី ជួងសាលាខ្ញុំរោទ៍ឮគ្រលួច ។ ពួកយើងជាសិស្សទាំងអស់គ្នាឈប់ប្រដេញគ្នាលេង ហើយរត់មកឈរតំរៀបគ្នាជាជួរ នៅមុខថ្នាក់រៀនខ្លួន ។ លោកគ្រូដើរតាមបន្ទោះជួរ ពិនិត្យមើលដៃ មុខ និងសំលៀកបំពាក់យើងគ្រប់គ្នា ហើយលោកមានប្រសាសន៍ថា "សិស្សសាលាត្រូវតែថែទាំខ្លួនប្រាណឲ្យស្អាត" ។ ពិនិត្យរួចហើយ លោកគ្រូលើកដៃធ្វើជាសញ្ញាប្រាប់យើង ឲ្យចូលក្នុងកន្លែងរៀន ។ យើងដើរសំដៅទៅកន្លែងរៀនខ្លួន ដោយស្ងៀមស្ងាត់ ។

---

*រោទ៍* (ម. ថ. រោ) ។ *សិស្ស* (ម. ថ. សឹស) ។ *ប្រសាសន៍* (ម. ថ. សាស) ។



## ៣_ កន្លែងរៀនខ្ញុំ

ថ្នាក់ដែលខ្ញុំរៀន ឈ្មោះថ្នាក់កុមារដ្ឋាន ។ បណ្ដោយមានប្រវែងប្រាំពីរម៉ែត្រ ទទឹងប្រាំមួយម៉ែត្រ ។ ទ្វារនឹងបង្អួចលាបព័ណ៌បៃតងខ្ចី ។ នៅក្នុងកន្លែងរៀនខ្ញុំ តុគ្រូដាក់លើក្ដារកំណាល់ជិតក្ដារខៀន ។ នៅមុខតុគ្រូ មានតុសិស្សពីរជួរ។ នៅក្បែរជញ្ជាំង ខាងក្រោយតុសិស្ស មានទូកញ្ចក់មួយធំខ្ពស់ភ្លឺរលោង គឺនៅក្នុងទូនោះហើយ ដែលលោកគ្រូខ្ញុំដាក់របស់គ្រប់មុខ សំរាប់បង្រៀនសិស្ស ។

កន្លែងរៀនខ្ញុំស្អាតណាស់ ហើយសប្បាយផង ។

---

ប្រាំពីរ គេថា (ព្រាំពីល) តាមសំដីអ្នកស្រុកដែលធ្លាប់ប្រើមកហើយ ។

## ៤– ប្រដាប់ប្រដារបស់សិស្ស



ប្រដាប់ប្រដាសិស្ស គឺសៀវភៅសរសេរ សៀវភៅមើល ដងប៉ាកកា ខ្មៅដៃ បន្ទាត់ ជ័រលុប ក្រដាសផ្ដិត ដបទឹកខ្មៅ ។ បើគ្មានក្រដាសផ្ដិតទេ សៀវភៅសរសេរមុខតែមិនស្អាតឡើយ ។ ខ្មៅដៃសំរាប់គូរគំនូរ ។ ជ័រលុបសំរាប់លុបអក្សរឬគំនូរដែលគូរពុំទាន់ត្រឹមត្រូវ ។ ដបទឹកខ្មៅត្រូវបុកឲ្យជិត ដើម្បីកុំឲ្យកំពប់ និងកុំឲ្យធូលីចូលផង ។

សិស្សត្រូវមានប្រដាប់ទាំងអស់នេះ ហើយត្រូវថែរក្សាកុំឲ្យបាត់បង់ឡើយ ។ ត្រូវប្រយ័ត្នកុំឲ្យធ្លាក់ខ្មៅដៃ ពីព្រោះវាបាក់បណ្ដូលនៅខាងក្នុង ។

---

ប្រយ័ត្ន (ម. ថ. ប្រ - យ៉ាត់)



## ៥_ សិស្សល្អ

នារីជាសិស្សល្អ មករៀនរាល់ថ្ងៃតុំដែលឈប់ ហើយទៀងពេលវេលាផង ។ សំលៀកបំពាក់សិស្សនេះស្អាតជាដរាប ។ នារីចាំមេរៀនស្ទាត់គ្រប់មុខ ។ កិច្ចការដែលគ្រូដាក់ឲ្យទៅធ្វើឯផ្ទះទាំងប៉ុន្មាន នារីធ្វើទាំងអស់ ។ នៅក្នុងកន្លែងរៀន នារីមិនហ៊ានប្រលែងលេងនឹងសិស្សដែលអង្គុយជិតខាងទេ នាងប្រឹងប្រយ័ត្នស្ដាប់គ្រូពន្យល់ ។ សេចក្ដីដែលគ្រូពន្យល់ទាំងអម្បាលម៉ាន នាងចាំទាំងអស់ ។ នារីជាក្មេងឧស្សាហ៍ ហើយឆ្លាតផង ។ គ្រូស្រឡាញ់សិស្សនេះណាស់ ដល់ចុងឆ្នាំ នារីបានរង្វាន់ ហើយបានឡើងថ្នាក់ផង ។

---

១ ឧស្សាហ៍ (ម.ឋ. អ៊ុស សា)



## ៦– ពេលចេញលេង

ម៉ោងប្រាំបួនម្ភៃប្រាំនាទី ខ្ញុំឮសូរជួងរោទ៍សម្លេងយ៉ាងស្រួយ គឺដល់ពេលចេញលេង ។ គ្រូគ្រប់ថ្នាក់បើកឲ្យសិស្សចេញទាំងអស់ ។ ខ្ញុំរត់លេងយ៉ាងសប្បាយក្នុងទីធ្លា ។ ខ្ញុំឮសូរមាត់សិស្សជជែកគ្នាអ៊ូអរអឺងកង ។ ខ្លះសើច ខ្លះហៅកញ្ជ្រៀវយ៉ាងខ្លាំង ខ្លះលេងប្រដេញគ្នា ខ្លះទាត់សី ខ្លះទៀតលោតអន្ទាក់ខ្សែ ។ សិស្សធំ ៗ ខ្លះឈរផ្អែកក្រោមដើមឈើមើលក្មេងតូច ៗ លេង ។

លោកគ្រូទាំងឡាយដើរទៅដើរមកត្រួតត្រាមើលសិស្ស ។

# ៣_ សំឡាញ់ខ្ញុំ



នៅក្នុងថ្នាក់ខ្ញុំ ខ្ញុំមានសំ-ឡាញ់ម្នាក់ឈ្មោះណារ៉ាឌី ។ វាបងខ្ញុំពីរឆ្នាំ ។ វាជាសិស្សប្រកបដោយកិរិយាមារយាទល្អប្រពៃព្រមទាំងមានប្រាជ្ញាវៃផង ។ វាចេះជួយធុរៈក្មេងណាដែលតូចជាងវា ។ ដើរតាមផ្លូវ វាមើលខុសត្រូវ ហើយជួយការពារក្មេងតូច ៗ មិនឲ្យមានគ្រោះដោយយានជំនិះផ្សេង ៗ ។ កាលណាវាបានចំណីឆ្ងាញ់បរិភោគ វាចែករំលែកឲ្យខ្ញុំ ឬឲ្យក្មេងណាដែលជាកូនអ្នកក្រលំបាក ។

សិស្សទាំងអស់ចូលចិត្តលេងជាមួយនឹងណារ៉ាឌីណាស់ ។



## ៨– គ្រូខ្ញុំ

គ្រូខ្ញុំឈ្មោះលោកសារី មាឌធំមាំខ្ពស់ សម្លេងគ្រលរ ។ លោកមកដល់សាលារៀន មុនម៉ោងជាដរាប ។ សំលៀកបំពាក់លោកស្អាតណាស់ ពុំដែលប្រាក់ផ្ដត់ទេ ។ លោកបង្រៀនសិស្សដោយយកចិត្តទុកដាក់ ហើយមានចិត្តសន្ដោសផង ។ លោកធ្វើទោសតែសិស្សណា ដែលខ្ជិលមិនចាំមេរៀន ។ គ្រូខ្ញុំសុចរិតណាស់ លោកសរសើរ ហើយឲ្យរង្វាន់បំពោះសិស្សណាដែលឧស្សាហ៍រៀនសូត្រ ។

ខ្ញុំស្រឡាញ់គ្រូខ្ញុំណាស់ ហើយខ្ញុំមិនភ្លេចគុណលោកទេ ។

# ៩– ខ្លួនមនុស្ស



លោកគ្រូឲ្យណារ៉ានី ទៅឈរនៅមុខសិស្សទាំងអស់គ្នា ។ លោកមានប្រសាសន៍ថា យើងសង្កេតមើលខ្លួនណារ៉ានីតើមានអ្វីខ្លះ ។ នៅខាងលើ ហៅថាក្បាល ចុះមកគឺដងខ្លួន ក្រៅអំពីចំណែកនោះ ខាងលើមានដៃ ខាងក្រោមគឺជើង ។ ដៃជើងរួមទាំងអស់ទៅ គេឲ្យឈ្មោះថា អវយវៈ ។

លោកគ្រូសួរទៅណារ៉ានីថា ប្រសិនបើគេកាត់ក្បាល ហើយនិងអវយវៈចេញ តើនៅសល់អ្វី ? ណារ៉ានីញញឹម ហើយឆ្លើយថា សូមជំរាបលោកគ្រូ បើដូច្នោះនៅសល់តែដងខ្លួនទេ ។

---

ប្រសាសន៍ (ម. ថ. ប្រ-សាស)

# ១០– អំពីក្បាល



មនុស្សយើងមានមុខ មាត់មិនដូចគ្នាទេ ។ ក្បាលសាលីមូលសំប៉ែត មុខប្របូញ ។ សក់ខាងណារីខ្មៅរលោងវែង ហើយរួញៗ ។ ចិញ្ចើមគូកនខ្ញុំក្រាស់ ភ្នែកវាក្រឡោត ។ ច្រមុះបងប្រុសខាងណារីស្រួចហើយកោង ។ មាត់ណារ៉ីនីតូច បបូរមាត់ស្ដើង ។ នៅក្នុងមាត់មានធ្មេញ ហើយនឹងអណ្ដាត ។ ធ្មេញម្ដាយខ្ញុំស ហើយដុះតំរៀបគ្នាជាជួរល្អណាស់ ។ បង្កាឪពុកខ្ញុំស្រួច ស្លឹកត្រចៀកគាត់ធំហើយក្រាស់ ។

មនុស្សយើងសំគាល់គ្នាទៅវិញទៅមកដោយសារមុខ ។

## ១១_ អំពីដៃ



យើងម្នាក់ៗ មានដៃពីរ ។ ដៃមួយៗ មានដើមដៃ កំភួនដៃ និងចុងដៃ ។ ត្រង់ណាដែលហៅថាកំភួនដៃ ? គឺតាំងពីកែងដៃរហូតទៅដល់កដៃ ។ ដៃនីមួយៗ មានម្រាមប្រាំ ដៃទាំងពីរមានម្រាមដប់ ។ នៅចុងម្រាមមានក្រចក ។ ដៃជាប្រដាប់មួយសំខាន់របស់មនុស្ស ។ បើគ្មានដៃ យើងនឹងរកស៊ីធ្វើការអ្វីមិនបានឡើយ ។ មនុស្សណាដែលកំបុតដៃ ធ្វើការអ្វីពុំបាន មនុស្សនោះនឹងរងទុក្ខវេទនាអស់មួយជីវិត ។

យើងត្រូវកាត់ក្រចកដៃជារឿយៗ ។

## ១២_ អំពីជើង



យើងមានជើងពីរ ។ ជើងជាប់នឹងដងខ្លួនត្រង់ត្រគាក ។ ជើងម្ខាង ៗ មានភ្លៅ ជង្គង់ កំភួនជើង នឹងចុងជើង ។ នៅចុងជើងមានម្រាមប្រាំ ។ នៅចុងម្រាមមានក្រចករឹងជាងក្រចកដៃ ។ យើងដើរ រត់ លោត នឹងជើង ។ ដូច្នេះ ជើងក៏ដូចជាដៃដែរ គឺជាប្រដាប់សំខាន់របស់មនុស្សយើង ។ មនុស្សណាដែលបាក់ជើងស្វិតជើងដើរពុំបាន ហៅថា មនុស្សខ្វិន ។

យើងត្រូវប្រយ័ត្នថែដៃជើងរបស់យើងកុំឲ្យបាក់ ។

# ១៣_ សាច់ដុំ



នៅជិតសាលារៀនខ្ញុំ មានជាងឈើម្នាក់ឈ្មោះម៉ម ។ ពូម៉មមានមាឌធំ ហើយមាំផង ។ កាលណាគាត់កាន់ដែកឈូស ៗឈើ ខ្ញុំឃើញដើមដៃគាត់ ឡើងប៉ោងដូចគេសប់ ។ ភ្លៅនឹងកំភួនជើងគាត់មើលទៅឃើញតែសាច់ដុំ ។ គាត់ឈរឈូសឈើ ធ្វើព្រងើយដូចជាគ្មានអស់កម្លាំងសោះ ។ ខ្ញុំសួរគាត់ថា "ពូ! ហេតុម្ដេចក៏ដៃជើងខ្ញុំមិនដូចដៃជើងពូ?" ។ គាត់ឆ្លើយថា: "បើក្មួយចង់ឲ្យមានសាច់ច្រើនដូចពូ ចូរក្មួយកុំស្អប់ខ្ពើមការហាត្ថកម្ម" ។



## ១៤– វិធីហាត់ប្រាណ

សិស្សត្រូវហាត់ប្រាណរាល់ថ្ងៃ នៅវេលាល្ងាចដែលចេញពីរៀន ។ បើលោកគ្រូបង្គាប់ឲ្យលើកដៃ ឬលើកជើងដូចម្ដេចត្រូវតែធ្វើតាម ។ យើងមិនត្រូវរត់ពួនគេបវៀះទៅលេងឯណោះឯណោះទេ ។ វិធីហាត់ប្រាណមិនគ្រាន់តែលើកដៃជើងប៉ុណ្ណោះទេ នៅមានលេងប្រដេញគ្នា រត់លោតយ៉ាងសប្បាយ នាំឲ្យបែកញើស ។ ធ្វើយ៉ាងនេះ យើងអស់កម្លាំងបន្តិច តែយើងនឹងបរិភោគបានច្រើន ។

វិធីហាត់ប្រាណ នាំឲ្យមានកម្លាំងកំហែង មានសាបឈាមថ្លាល្អ ។



## ១៥– ការសំអាតខ្លួនប្រាណ

រាល់ព្រឹកណារ៉ាឌីភ្ញាក់ពីព្រលឹម ។ វាយកសៀវភៅមកមើលមេរៀនរបស់វាឡើងវិញ មួយស្របក់ទើបវាដើរទៅក្នុងបន្ទប់ទឹក ។ វាយកសាប៊ូមកលាងដៃ ដុសធ្មេញ រួចវាងូតទឹក ។ វាដុសលាងខ្លួនប្រាណ ជើងដៃ នឹងសាប៊ូពុំដែលខានទេ ។ វាជូតខ្លួនវានឹងកន្សែងពោះគោ រួចវាឡើងទៅលើផ្ទះវិញ ។ វាផ្ទះកញ្ចក់ សិតសក់នឹងក្រាសយ៉ាងស្អាត ។

ណារ៉ាឌីស្អាតជានិច្ច ។ វាមិនដែលមានកមរមាស់ទេ ។



## ១៦- ណារ៉ាឌីស្លៀកពាក់

ណារ៉ាឌីសំអាតខ្លួនរួចហើយ វាម្មីម្មាទៅយកខោខ្លីមកស្លៀក ។ ដើម្បីកុំឲ្យរបូតខោ វាក្រវាត់បង្កេះវានឹងខ្សែក្រវាត់ស្បែកមួយ ដែលវាប្រើយូរណាស់មកហើយ ។ ស្លៀកពាក់រួចស្រេច ទើបណារ៉ាឌីស្រស់ស្រូបអាហារ ។ វាប្រមូលប្រដាប់ប្រដាវាទៅសាលារៀន ។

ណារ៉ាឌីពាក់មួកសំបុក សំរាប់ការពារក្បាលវា នឹងកំដៅព្រះអាទិត្យ ។ វាពាក់ស្បែកជើងឈើប្រយោជន៍កុំឲ្យឈឺជើងវា ក្នុងវេលាដែលដើរតាមផ្លូវ ។

## ១៧– អំពីសំលៀកបំពាក់



លោកគ្រូយើងស្លៀកខោបារាំង ជើងវែង ពាក់អាវបើកក ហើយមានបង "ក្រាវ៉ាត់" ផង ។ លោកពាក់ស្រោមជើងស និងស្បែកជើងខ្មៅ ។

បើលោកមានការដើរទៅក្នុងផ្លាសាលា លោកយកមួកសមកពាក់ ។

នៅក្នុងផ្ទះ លោកផ្លាស់ខោអាវដែលរាយឈ្មោះខាងលើនេះចេញ ។ លោកយកសារុងមកស្លៀក ហើយពាក់អាវទ្រ-ទាប់ស្តើង ។ ក្នុងផ្ទះលោកមិនដើរជើងទទេទេ លោកពាក់ស្បែកជើងផ្ទាត់ ។



## ១៨- អំពីសំលៀកបំពាក់ខ្មែរ

ថ្ងៃនេះ មានបុណ្យមួយនៅក្នុងវត្ត ។ អ្នកស្រុកស្រែបញ្ចេញ សំលៀកបំពាក់យ៉ាងល្អ ៗ ។ ប្រុស ៗ ស្លៀកសំពត់ផាមួងចង ក្បិន ពាក់អាវកត្រង់ ដាក់ខ្សែរទង់ហ្វា ។ ក្មេងស្រី ៗ ស្លៀក ហូល ពណ៌ស្រស់ ហើយពាក់អាវបំពង់ព្រៃ ពណ៌ ខៀវ បៃតង ផ្កាត្របែក ផ្កាឈូក ។ ចាស់ ៗ ស្លៀកខៀនពាក់អាវសខ្លី ហើយ បង់ក្រមា ។

អ្នកមានពាក់ទំហូដាំពេជ្រ បន្តោងក ខ្សែដៃ ចិញ្ចៀន អង្គាំមាស ។ អ្នកខ្លះមានទាំងនាឡិកាបង់ដៃផង ។



## ១៩– អំពីផ្ទះខ្មែរ

រាល់ថ្ងៃ ដល់ពេលចេញពីសាលារៀន ខ្ញុំត្រឡប់ទៅផ្ទះខ្ញុំ ។ ផ្ទះខ្ញុំនៅក្រោយផ្ទះលោកមេឃុំ ។ ផ្ទះខ្ញុំជាផ្ទះខ្មែរបុរាណ សង់ពីឈើខ្ពស់ពីដី ប្រក់ក្បឿងក្រហម ជញ្ជាំងក្ដារ ។ ពីមុខគេឃើញទ្វារមួយ បង្អួចពីរ ។ ជណ្ដើរធ្វើអំពីឈើកកោះ ហើយមានបង្កាន់ដៃផង ។

ផ្ទះខ្ញុំសមណាស់ តែចាស់បន្តិចទៅហើយ ។ ដល់កាលណាខ្ញុំធំ ខ្ញុំខំសន្សំប្រាក់កាស ដើម្បីនឹងសង់ផ្ទះឲ្យយ៉ាងល្អ ។



២០– អំពីផ្ទះខ្មែរ (គ)

ផ្ទះខ្ញុំមានបីល្វែង ។ នៅល្វែងកណ្ដាល មានទ្បប់ទ្បែមួយ ។ បំណែកខាងមុខទ្បប់ទ្បែនេះ ទុកសម្រាប់ទទួលភ្ញៀវ ។ នៅកន្លែងនេះ មានក្ដារងៀនាងនួនមួយ តុបេងមួយ ហើយនឹងកៅអីស្រទ្បាបួន ។ នៅលើជញ្ជាំង គេឃើញមាននាទ្បិកានឹងរូបថត ។ ខាងក្រោយទ្បប់ទ្បែ ជាកន្លែងបរិភោគអាហារ ។ ផ្ទះបាយនៅខាងក្រោយផ្ទះធំ ។

នៅក្នុងផ្ទះខ្ញុំ ត្រជាក់ណាស់ ឪពុកម្ដាយបងប្អូនខ្ញុំនៅបានសេចក្ដីសុខសប្បាយរៀងរហូតដល់សព្វថ្ងៃ ។



## ២១– អំពីគ្រួសារខ្ញុំ

ឪពុកខ្ញុំធ្វើស្រែផង ធ្វើចំការផង ។ គាត់នឿយលំបាកណាស់ ។ ម្ដាយខ្ញុំតុបតែងផ្ទះ ហើយមើលថែរក្សាកូនតូចៗ។ គាត់ព្រួយបារម្ភជានិច្ច ។ បងស្រីខ្ញុំធ្វើម្ហូបឲ្យគ្រួសារបរិភោគរាល់ថ្ងៃ ។ គាត់បោក លាង ដេរ ប៉ះ សំលៀកបំពាក់របស់យើងទាំងអស់គ្នា ។ ឯចំណែកខាងខ្ញុំ ខ្ញុំទៅរៀនឯសាលា ។

ខ្ញុំខំរៀនសូត្រឲ្យបានចេះដឹង ហើយឲ្យឪពុកម្ដាយសប្បាយចិត្ត ។

## ២២- ជីតាខ្ញុំ



ជីតាខ្ញុំ អាយុប៉ែតសិបពីរឆ្នាំ ។ សក់គាត់ស្កូវព្រោង ខ្នងកោង ស្បែកជ្រីវជ្រួញ ថ្ពាល់ខួង មាត់គ្រហុប ។ គាត់ដើរបាន ដោយទប់នឹងឈើច្រត់ ។ គាត់ធ្វើការធ្ងន់មិនបានទេ ។ គាត់នៅផ្ទះមើលថែទាំប្អូនខ្ញុំ ។

ជីតាខ្ញុំ តែងនិទានរឿងព្រេងឲ្យខ្ញុំស្តាប់ ។ គាត់និយាយប្រាប់ខ្ញុំជារឿយៗ អំពីហេតុភេទដែលកើតឡើង កាលគាត់នៅពីក្មេង ។ គាត់ទូន្មានខ្ញុំជាញឹកញយ ឲ្យខ្ញុំបានប្រកបដោយគន្លងច្បាប់ ។




## ២៣ – ពេលបរិភោគ

ឥឡូវនេះ ថ្ងៃត្រង់ហើយ គឺជាពេលទទួលទានបាយ ។ បងស្រីខ្ញុំគាត់លើកថាសម្ហូបមក មានសំឡត្រីជៀន អន្លក់ ទឹកគ្រឿង ។ ខ្ញុំជញ្ជូនចាន ហើយនឹងក្លាំដែលបងស្រីខ្ញុំដាក់បាយ ។

ក្រុមញាតិរបស់ខ្ញុំអង្គុយជុំវិញថាសម្ហូប ។ ម្នាក់ៗ មានចានបាយមួយដាក់ពីមុខ ។ ឪពុកខ្ញុំចាប់អាហារនឹងបង្កើះ ។ យើងរាល់គ្នាចាប់នឹងដៃ ហើយយកស្លាបព្រាដួសសំឡ ។

បងប្អូនខ្ញុំ នឹងខ្ញុំបរិភោគដោយស្ងៀមស្ងាត់ ។



## ២៤_ អំពីសត្វ

មានសត្វច្រើនដែលនៅជិតយើង ។ គោអូសរទេះ ។ ក្របីទាញនង្គ័ល ។ គេប្រើសេះជាជំនិះ ។ ជ្រូកយើងយកសាច់នឹងខ្លាញ់វា ។ មាន់-ទាយើងយកពងនឹងសាច់ ។ ឆ្កែថែរក្សាផ្ទះសំបែងទាំងយប់ទាំងថ្ងៃ ។ ឆ្មាចាប់កណ្ដុរដែលជាសត្វចង្រៃ ។

សត្វដែលគេចិញ្ចឹមទាំងនេះ មានប្រយោជន៍ណាស់ ។ យើងត្រូវបំប៉នបំណាំអាហារ ហើយមិនត្រូវធ្វើបាបវាឡើយ ។

នៅក្នុងផ្ទះយើង មានសត្វខ្លះ ដែលជាសត្រូវនឹងយើងដូចជាមូសហើយនឹងសង្កើច ។

## ២៥– ឆ្កែខ្ញុំ




ឆ្កែខ្ញុំពូជឆ្កែខ្មែរ ។ មាឌវាធំល្មម ។ រោមវាខ្លីហើយខ្មៅ ។ វាមានពពាលសនៅលើក្បាល ។ ស្លឹកត្រចៀកវាបាក់ ។ កន្ទុយវាកំបុត ។

កាលណាខ្ញុំមកពីសាលារៀន វារត់ទៅទទួលខ្ញុំ ។ វាលិទ្ធជើងដៃខ្ញុំ ហើយវាបក់កន្ទុយផង ដូចជាវាបង់សួរសុខទុក្ខរបស់ខ្ញុំ ។ កាលណាខ្ញុំដើរទៅលេងនៅទីណា វាទៅតាមខ្ញុំ ។

ឆ្កែខ្ញុំមិនកាបទេ ។ វាគ្រាន់តែព្រូស តែវាមិនខាំទេ ។



## ២៦- អំពីក្របី

អ្នកនៅជិតខាងខ្ញុំ មានក្របីមួយនឹម ។ ក្របីទាំងពីរនេះដូចគ្នាបេះបិទ ។ មាឌវាធំមាំ ហើយខ្ពស់ជាងគោ ។ សម្បុរវាប្រផេះ ។ ស្នែងវាវែង កោងខុបរកគ្នា ។

សត្វនេះចូលចិត្តទឹកភក់ជាងកំដៅព្រះអាទិត្យ ។ ហេតុនេះបានជាអ្នកស្រែច្រើនប្រើក្របីឲ្យទាញនង្គ័ល ឬរនាស់ ។

ក្នុងពេលក្ដៅ វាដេកត្រាំទឹក ឬត្រាំភក់ ទំពាអៀងបណ្ដើរ ។

ក្របីជាសត្វបំរើ ស្លូតណាស់ ហើយខ្លាំងផង ។



## ២៧- អំពីភូមិខ្ញុំ

ខ្ញុំនៅភូមិសំរោង ។ ភូមិនេះតូចទេ នៅជិតមាត់ស្ទឹង ។ នៅក្នុងភូមិខ្ញុំ មានខ្មែរ-ចិន-យួន ។ ខ្មែរធ្វើស្រែ ឬ ចំការ ទីលំនៅច្រើនធ្វើអំពីឈើ ខ្ពស់ពីដី ។ ចិន ជាអ្នក ជំនួញ ហើយធ្វើផ្ទះទាបនឹងដី នៅជិតថ្នល់ ។ យួនច្រើនរកស៊ីនេសាទត្រី ហើយធ្វើផ្ទះសម្បែងនៅក្បែរមាត់ប្រាំង ។

អ្នកស្រុកភូមិខ្ញុំ ច្រើនតែមនុស្សត្រឹមត្រូវ ។ គេមិនឈ្លោះប្រកែកគ្នាទេ ។ គេគិតតែបបួលគ្នាធ្វើការរកស៊ី ។



## ២៨- ផ្ទះលក់ទំនិញ

នៅក្នុងភូមិខ្ញុំ មានផ្ទះលក់ទំនិញច្រើន ។ ផ្ទះពូសំមាន មនុស្សចេញចូលកុះករជាងគេ ។

នៅខាងមុខ គេឃើញកញ្ចើ សណ្ដែក មីសួ ត្រីងៀត ត្រីឆ្អើ(រ)ខ្ទឹមបារាំង ខ្ទឹមស ដាក់តំរៀបគ្នា ។ នៅខាងក្នុងជិតជញ្ជាំង មានទូកញ្ចក់ពីរ ។ នៅថ្នាក់លើ គេរៀបសំពត់ ខោអាវ ដបទឹកអប់ ដបថ្នាំ ។ នៅថ្នាក់ក្រោម គេឃើញមានដប ស្រា ដប"លីម៉ូណាត" ប្រអប់ត្រី១ ។



## ២៩– អំពីផ្សារ

ផ្សារសង់នៅចំកណ្ដាលភូមិ ហើយជិតមាត់ស្ទឹង ។ ផលដំណាំទាំងប៉ុន្មានរបស់អ្នកស្រុក មូលទៅនៅតែងផ្សារ ។ គេគរបន្លែលើរាន ហើយដាក់ផ្លែឈើក្នុងល្អី ។ គេរៀបត្រីនៅលើកំណាត់កន្ទេលដែលក្រាលលើដី ។ មាន់ ទា ស្រែកកញ្ជ្រោលនៅក្នុងទ្រុង ដែលគេធ្វើពីឫស្សី ។ គេដាក់សាច់គោ សាច់ជ្រូកនៅលើតុឈើ ។ អ្នកទិញដើរទៅដើរមករកទិញអីវ៉ាន់ ។

នៅផ្សារគេឮតែសូរមាត់អ្នកលក់នឹងអ្នកទិញ ។



## ៣០_ អំពីជាងឈើ

ពូម៉ក់កំពុងតែធ្វើហិបមួយ ។ គាត់យកក្ដារមួយសន្លឹកមកអារកាត់ជាកំណាត់ ៗ ។ គាត់ឈូសកំណាត់ក្ដារនេះយ៉ាងស្អាត ហើយគាត់វាយភ្ជាប់គ្នានឹងដែកគោល ធ្វើបាតហិប ។ គាត់វាយក្ដារជុំវិញបាតនេះរួចហើយ គាត់ធ្វើគ្រប ។

ពូម៉ក់មិនធ្វើតែហិបទេ ។ គាត់ធ្វើ តុ ទូ ជើងម៉ា កៅអី ដែរ ។ នៅក្នុងរោងគាត់ គេឃើញតែកំទេចឈើ អាចម៍រណារ ហើយនឹងអាចម៍ដែកឈូស ។



## ៣១– អំពីជាងដែក

កាលពីថ្ងៃអាទិត្យដែលកន្លងទៅហើយនោះ ខ្ញុំយកដែកមួយដុំទៅឲ្យជាងគ្រួបធ្វើកាំបិត ។ គាត់កំពុងតែដុតដែកមួយបន្ទះ ។ លុះដែកនេះឡើងក្រហម គាត់ចាប់ដែកនេះនឹងដង្កៀបមួយវែង គាត់ដាក់ទៅលើដែកទ្រនាប់ រួចគាត់ដំនឹងញញួរមួយធំ ។ ជាងគ្រួបគាត់ធ្វើ កាំបិត ពូថៅ ចប ។

នៅកន្លែងនេះ តាំងពីព្រលឹមលុះដល់ព្រលប់ គេឮតែស្នូរញញួរដូចជាពីរោះដែរ ។



## ៣២– អំពីវត្តនៅក្នុងភូមិខ្ញុំ

ម្ដាយខ្ញុំគាត់ទៅវត្តរាល់តែថ្ងៃសីល ។ វត្តនេះនៅខាងត្បូងភូមិលើដីទួល ។ នៅខាងជើងព្រះវិហារ គេឃើញកុដិលោកគ្រូសង្ឃរាជហើយនឹងសាលាឆាន់ ។ តូបលោកបរិសទ្យនៅខាងក្រោយព្រះវិហារ ។ ស្រះពីរនៅខាងមុខព្រះវិហារមានទឹកថ្លាឈ្វេង ហើយមានឈូកស ក្រហម ដុះចម្រុះគ្នា ។ នៅជិតស្រះ ខាងជើងក្បែរថ្នល់ មានសាលាសំណាក់មួយ ។



## ៣៣– អំពីដើមឈើ

នៅក្នុងធ្លាវត្តមានដើមឈើជាច្រើន គឺដើម ពោធិ៍ ដើមដូង ដើមត្នោត ដើមស្វាយ ។ ដើមស្វាយមួយនោះ ចាស់ណាស់ ហើយ ឫសវាចាក់ជ្រែកទៅក្នុងដីគ្រប់ទិស ។ ដើមវាធំមូល តែទាបទេ ។ នៅក្លែងខ្លះ គេស្មោះសំបកធ្វើថ្នាំ ។ មែកបែកសាខា ។ មានពេលណា ស្លឹកជ្រុះអស់រលីង ។ រួចអំពីនោះ មិនយូរប៉ុន្មាន មានស្លឹក ផ្កា ផ្លែ ឡើងវិញ ។ ក្នុងផ្លែនីមួយៗមាន សំបក សាច់ ហើយ នឹង គ្រាប់តែមួយ ។



## ៣៤_ អំពីដើមដូង

ខ្មែរយើងច្រើនដាំដើមដូងនៅក្បែរផ្ទះ ។ ដើមដូងមូលត្រង់ហើយខ្ពស់ ។ ដើមដូងគ្មានមែកទេ មានតែធាង ។ ស្លឹកវាវែងហើយស្រួច ។ ផ្លែវាមូល ហើយផ្តុំគ្នាជាធ្លាយ ។ ក្នុងផ្លែនីមួយៗ មានសំបករលោ សាច់ហើយនឹងទឹក ។

ដើមដូង ជារុក្ខជាតិមានប្រយោជន៍ណាស់ ។ គេយកឫសវាធ្វើជាថ្នាំកែរោគ ។ ដើមប្រើធ្វើជាទទឹក ឬជាសសរ ។ ស្លឹកសំរាប់គុបតែងលំអរោងបុណ្យទាន ។



## ៣៥– នៅស្រុកស្រែ

រដូវវស្សា អ្នកធ្វើស្រែនឿយណាស់ ។ ខ្លះដើរតាមនង្គ័ល ក្នុងទឹក នៅវេលាថ្ងៃក្ដៅ ដើម្បីនឹងភ្ជួរស្រែ ។ ខ្លះទៀតឈរនៅលើរនាស់គ្រវីត្មោងកំញើញគោ ឬក្របី ឲ្យវាប្រឹងដើរដោយរួសរាន់ ។ ស្រី ៗ ណាត់សំពត់ឬខោ បុះទៅក្នុងភក់ត្រឹមជង្គង់ ដើម្បីនឹងដក ឬ ស្ទូងស្រូវ ។ ក្មេង ៗ អង្គុយលើខ្នងគោ ឬក្របី បណ្ដោយឲ្យស៊ីស្មៅតាមភ្លឺស្រែ ។



## ៣៦–នៅស្រុកស្រែ (ត)

ក្នុងរដូវលំហើយ វេលាដែលខ្យល់ត្រជាក់បកមកពីទិសឯជើង ស្រូវស្រែទុំក្រហមឆ្អៅ ។ ប្រុសស្រីភ្ញាក់ពីព្រលឹមជូតក្បាលធំសំពោងនាំគ្នាទៅស្រែ ។ អ្នកទាំងនេះកាន់កណ្តៀវមួយម្នាក់ៗទៅច្រូតស្រូវ ។ គេចងដើមស្រូវជាកណ្តាប់ រួចគេប្រមូលយកទៅរៀបជាគំនរក្នុងលាន ។ ខ្មែរយើងបេះលើកដៃគ្នាច្រូតស្រូវយ៉ាងរហ័ស ។

ក្នុងវាលស្រែគេឮតែបម្រៀងដែលប្រុសស្រីច្រៀងតគ្នា ។

---

រហ័ស (ម. ឋ. រ.ហាស់) ។



## ៣៧– ដំណើរតាមកប៉ាល់

ណាវ៉ាឌី ត្រូវទៅសួរបងវាឈឺនៅឯក្រុងភ្នំពេញ ។ វារៀបសំលៀកបំពាក់របស់វា ដាក់ក្នុងហឹបមួយតូចតាំងពីល្ងាច ។ លុះដល់ព្រឹកឡើងវាទៅចុះកប៉ាល់ ។ វាអង្គុយនៅលើជើងម៉ាជិតបំពង់ភ្លើង ។ លុះកប៉ាល់ចេញបានបន្តិចទៅ ចិនជួមកទារថ្លៃកប៉ាល់ ហើយគេឲ្យបង្កាន់ដៃមួយសន្លឹក ។ នៅក្នុងកប៉ាល់ចុះមួយជើង ៗ មានអ្នកដំណើរច្រើនណាស់ ។




## ៣៨– អំពីក្រុងភ្នំពេញ

នៅក្រុងភ្នំពេញ ណាវ៉ីមិនហ៊ានដើរលេងតែម្នាក់ឯងទេ ពីព្រោះមានផ្លូវជាច្រើនកាត់គ្នាខ្វាត់ខ្វែង ។ ផ្ទះពីរឬបីជាន់ដែលសង់តាមមាត់ផ្លូវ មានភាពប្រហែល ៗ គ្នា ។ រថយន្តតូច-ធំ ស៊ីក្លូ បរទៅបរមកឥតមានស្រាក ។ នៅតាមបំពង់ផ្លូវ មហាជនប្រជ្រៀតគ្នាដើររកទិញអីវ៉ាន់ ។ វេលាយប់ នៅក្នុងផ្ទះ ឬ ក្រៅផ្ទះភ្លឺដូចជាវេលាថ្ងៃ ដោយពន្លឺភ្លើងអគ្គិសនី ។

នៅទីក្រុងនេះ មានទំនិញគ្រប់មុខ ដែលមកពីប្រទេសក្រៅ ។



## ៣៩– ដំណើរតាមជើងគោក

ណារ៉ាឌីត្រូវត្រឡប់ទៅផ្ទះវិញ ។ ពីល្ងាចវាទៅរកទិញសំបុត្រ លុះដល់ព្រឹកឡើងវាទៅចាំនៅកន្លែងបំណាតរថយន្ត ។ មួយស្របក់រថយន្តមកដល់ ។ ណារ៉ាឌីឡើងលើរថយន្ត ហើយអង្គុយត្រង់កន្លែង ដែលមានលេខដូចគេត្រានៅក្នុងសំបុត្រ ។

ដល់ម៉ោង រថយន្តក៏ចេញពីកន្លែងបំណាត ។ ដំបូងគេបើកបន្តិចៗ ។ យូរទៅវារត់កាន់តែលឿនឡើងៗកាត់ភូមិ ឆ្លងស្ពានបុះសាឡាង ។



## ៤០– ព្រះអាទិត្យ និង ព្រះចន្ទ

ព្រះអាទិត្យរះនៅទិសឯកើត ។ ពេលលោកទៅនៅចំពីលើក្បាលយើងគេសន្មតជាថ្ងៃត្រង់ ។ ចាប់ពីពេលនេះទៅទល់នឹងថ្ងៃលិច នៅទិសខាងលិច គេថារសៀល ។ វេលាយប់ព្រះចន្ទធ្វើដំណើរដូចព្រះអាទិត្យ ។

ព្រះអាទិត្យ និង ព្រះចន្ទ ប្រដេញគ្នាយ៉ាងនេះ ឥតមានឈប់ឈរឡើយ ។ លុះដល់លោកប្រទះគ្នាម្ដង ៗ នៅពេលយប់ បុរាណយើងសន្មតថា រាហូចាប់ចន្ទ ។

សៀវភៅនេះ បោះនៅរោងពុម្ព ហង្ស-រី
ចំនួន ២០.០០០ ច្បាប់ នៅខែឧសភា ១៩៥៤ លេខ ១
តម្កល់ទុកតាមបញ្ញត្តិ — ត្រ័យមាសទី ២ ឆ្នាំ ១៩៥៤

សូមអញ្ជើញចូលមើល

# ហាង ហង្ស រី

លេខ ៩៣ ‒ ៩៥ ‒ ៩៧, វិថីអង្គអេង ក្រុងភ្នំពេញ

## មានទាំង

## រោងពុម្ព =

ដែលបានរៀបចំតាមទំនើបថ្មី

ការងារហ្មត់ចត់ ធ្វើតាមបង្គាប់

បោះពុម្ពសៀវភៅគ្រប់បែប :

ជាខ្មែរ — ជាបារាំង — ជាកុកងឺ — ជាចិន

ចងក្រងសៀវភៅយ៉ាងល្អវិសេស

ធ្វើការរហ័ស ហើយត្រឹមត្រូវ

## បណ្ណាគារ =

បោះពុម្ពផ្សាយសៀវភៅបារាំង សៀវភៅខ្មែរ

មានលក់សៀវភៅសម្រាប់រៀន ខ្មែរ បារាំង សុទ្ធសឹងតែបាន

ជ្រើសរើសយ៉ាងដិត ៗ ព្រមទាំងសៀវភៅប្រលោមលោកផង

មានលក់វិចនានុក្រមបារាំង និងរូបថតអ្នកសិល្បៈដ៏ចំណាន

## គ្រឿងប្រដាប់សរសេរ =

ទទួលលក់ជូនរាជការ :

= មានប្រដាប់សម្រាប់ប៊ុយរ៉ូ បែបក្រុងប៉ារីស

= មានប្រដាប់សម្រាប់សិស្ស

ក្រដាសសរសេរគ្រប់ខ្នាត — គ្រប់គុណ (លក់រាយ—លក់ដុំ)

មានសៀវភៅសរសេរ និងសៀវភៅបញ្ជី

## សូមអញ្ជើញតម្រូវមកចុះ យើងខ្ញុំនឹងធ្វើជូនឲ្យបានពេញចិត្ត